ក

# មាតិកា

***

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


២៧-៦-២០០០ - ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០០/១១៩ ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ជូនលោក អាសហ្សេន ដឺនីស ហ្សង់គ្រីស្ទង់ (ASTGEN DENIS JEAN CHRISTIAN) ១១២៧

២៧-៦-២០០០ - ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០០/១២០ តែងតាំងឯកឧត្តម មាស សុត្ថា ជាឧកញ៉ា ១១២៨

២៨-៦-២០០០ - ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០០/១២១ តែងតាំង លោកជំទាវ កេត សំអាត ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ១១២៨

២៨-៦-២០០០ - ព្រះរាជក្រឹត្យលេខ នស/រកត/០៦០០/១២២ តែងតាំងឯកឧត្តម នៅ ច័ន្ទតារា ជាឧបការិប្រធានរដ្ឋសភា ១១២៩


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២៦-៦-២០០០ - អនុក្រឹត្យ លេខ ៣៨ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌថ្មី ១១៣០

២៧-៦-២០០០ - អនុក្រឹត្យ លេខ ៣៩ អនក្រ.បក ស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ១១៣៣

២៦-៦-២០០០ - អនុក្រឹត្យ លេខ ២២២ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ ១១៣៦

៣០-៦-២០០០ - អនុក្រឹត្យ លេខ ២២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៣៧

៣០-៦-២០០០ - អនុក្រឹត្យ លេខ ២២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៣៩

៣០-៦-២០០០ - អនុក្រឹត្យ លេខ ២២៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១១៤០

| | | |
|---|---|---|
| ៣០-៦-២០០០ | - អនុក្រឹត្យ លេខ ២២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១១៥២ |
| ៣០-៦-២០០០ | - អនុក្រឹត្យ លេខ ២២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១១៥៣ |
| ៣០-៦-២០០០ | - អនុក្រឹត្យ លេខ ២២៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ១១៥៤ |
| ៣០-៦-២០០០ | - អនុក្រឹត្យ លេខ ២២៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ១១៥៥ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ២៤-៦-២០០០ | - សេចក្តីសំរេចលេខ ៤៥ សសរ ស្តីពីការផ្ទេរសិទ្ធិរាជរដ្ឋាភិបាល | ១១៥៦ |


# III- ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

### សារាចរណែនាំ


| | | |
|---|---|---|
| ២៧-៦-២០០ | - សារាចរណែនាំ លេខ ០០៣ សរណន.សក ស្តីពីការងារគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក | ១១៥៧ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៦០០/១១៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់បង្គាប់

មាត្រា ១ .-ផ្តល់សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ជូនលោក អាសហ្សេន ដឺនីស ហ្សង់គ្រីស្ទង់ ( ASTGEN DENIS JEAN CHRISTIAN ) កើតនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៦៩ នៅ BELFORT ប្រទេសបារាំង ដែលមានសញ្ជាតិដើម ជាបារាំង ។

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/០៦០០/១២០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

តែងតាំង

ឯកឧត្តម មាស សុត្ថា

ជា

ឧកញ៉ា

ធ្វើនៅព្រះបរមរាជវាំងភ្នំពេញ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

ព្រះរាជក្រឹត្យ នស/រកត/០៦០០/១២១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩៩៩/១០ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ។

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងលោកជំទាវ គេត សំអាត ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និង កិច្ចការទូទៅ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៦០០/១២២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០០០

-យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម នៅ ចំន្ទតារា ជាឧបការីប្រធានរដ្ឋសភា ដែលមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៣៨ អនក្រ.បក

### ស្តីពី ការបង្កើតគណៈកម្មការ សមាហរណកម្មមន្ត្រីរាជការស៊ីវិល នៅក្នុងក្របខ័ណ្ឌថ្មី

***

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត. ១២៩៧-២៧៣ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-តាមសំណូមពរចាំបាច់នៃការងារ

## សំរេច

**មាត្រា ១ .-**

ត្រូវបានបង្កើត គណៈកម្មការសមាហរណកម្ម មន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ដើម្បីផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីទាំងបួនប្រភេទ : ក ខ គ ឃ នូវមន្ត្រីរាជការ ស៊ីវិលទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅក្នុងរដ្ឋបាលកណ្តាល និងតាមខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .-**

គណៈកម្មការសមាហរណកម្ម មន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ប្រធាន |
| ២-រដ្ឋលេខាធិការមុខងារសាធារណៈ | អនុប្រធាន |
| ៣-សមាជិកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |
| ៤-តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៥-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៧-តំណាងក្រសួង មហាផ្ទៃ | សមាជិក |
| ៨-តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៩-តំណាងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ១០-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១-តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១២-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣-តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | សមាជិក |
| ១៤-តំណាងក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |

**មាត្រា ៣ .-**

ប្រធានគណៈកម្មការ មានសិទ្ធិអញ្ជើញអ្នកបច្ចេកទេស ឬ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់ ។

**មាត្រា ៤ .-**

គណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី មានភារកិច្ចដូចតទៅ :

១-ពិនិត្យសិក្សាស្រាវជ្រាវ ណែនាំរៀបចំលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរាជការផ្សេងៗទៀតក្រៅពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ក្នុងករណីចាំបាច់ ជាមួយក្រសួងពាក់ព័ន្ធ

២-សិក្សាស្រាវជ្រាវ លើកគោលការណ៍សំរាប់ការចាត់ថ្នាក់ធ្វើសមាហរណកម្មមន្ត្រីរាជការ បញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច

៣-រៀបចំកម្មវិធីសមាហរណកម្ម ដាក់អោយអនុវត្ត និងណែនាំ តាមដានការអនុវត្តន៍កម្មវិធីនៅតាមក្រសួងស្ថាប័ននានា

៤-ធ្វើសុពលកម្មលទ្ធផលនៃការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល បញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មី ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច

៥-ធ្វើសហប្រតិបត្តិការជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្ទៀងផ្ទាត់បញ្ចូលទិន្នន័យថ្មី នៃការងារសមាហរណកម្ម ទៅក្នុងប្រព័ន្ធគ្រប់គ្រងពត៌មានវិទ្យា ។

មាត្រា ៥ .-

គណៈកម្មការនេះ ស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

មាត្រា ៦ .-

គណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ធ្វើការក្រោមការដឹកនាំរបស់ប្រធានគណៈកម្មការ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង បុគ្គលិករបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ជាជំនួយការតាមការចាំបាច់ ។

មាត្រា ៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ៣៩ អនក្រ.បក

## ស្តីពី

## គោលការណ៍រួម នៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

***

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨២/អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការ ស៊ីវិល

-តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សំរេច

## ជំពូក ១

## នីតិវិធី នៃការគ្រប់គ្រងរដ្ឋបាល និង ហិរញ្ញវត្ថុរបស់មន្ត្រីរាជការស៊ីវិល

មាត្រា ១ .-

ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់មន្ត្រីរាជការស៊ីវិល មានការផ្លាស់ប្តូរតួនាទីរដ្ឋបាល និង ការផ្លាស់ប្តូរស្ថានភាពគ្រួសារ ត្រូវធ្វើឡើងដោយប្រព័ន្ធព័ត៌មានវិទ្យា ។

មាត្រា ២ .-

អង្គភាពទទួលបន្ទុកបុគ្គលិកនៅរដ្ឋបាលកណ្តាល ជាអ្នករៀបចំលិខិតបទដ្ឋានឯកត្តជនក្នុងការគ្រប់គ្រងរដ្ឋបាលមន្ត្រីរាជការស៊ីវិល មានសេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាង ប្រកាស ដោយប្រើប្រាស់ឯកសារធម្មនិយាមកម្មនៃពត៌មានវិទ្យា ដែលមានបញ្ជាក់អត្តលេខរបស់មន្ត្រីរាជការទាំងនោះគ្រប់ ។ ចាប់ពីពេលដែលដាក់អោយដំណើរការនូវប្រព័ន្ធគ្រប់គ្រងតាមពត៌មានវិទ្យាតទៅ លិខិតបទដ្ឋានឯកត្តជន ដែលបោះពុម្ពក្រៅពីឯកសារធម្មនិយាមកម្មនៃពត៌មានវិទ្យាត្រូវចាត់ទុកជាមោឃភាព ។

មាត្រា ៣ .-

លិខិតបទដ្ឋានឯកត្តជន ដែលជាប្រកាស ត្រូវផ្ទៀងផ្ទាត់លើសុពលភាពផ្នែករដ្ឋបាលដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងលើផ្នែកថវិកាដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ហើយត្រូវចុះទិដ្ឋាការរៀងៗខ្លួនលើលិខិតបទដ្ឋានឯកត្តជនទាំងនេះ នៅផ្នែកខាងឆ្វេង នៃហត្ថលេខារបស់ប្រធានស្ថាប័នសាមី ។ សេចក្តីព្រាងលិខិតបទដ្ឋានឯកត្តជនដែលជាអនុក្រឹត្យ និងព្រះរាជក្រឹត្យ ត្រូវផ្ទៀងផ្ទាត់លើសុពលភាពផ្នែករដ្ឋបាល ដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ លើផ្នែកថវិកាដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងត្រូវមានបន្ថែមទិដ្ឋាការពីទីស្តីការគណៈរដ្ឋមន្ត្រី ហើយដែលត្រូវចុះទៅក្នុងមូលបទទាំងអស់ ។

## ជំពូក ២
## ការទូទាត់ប្រាក់បៀវត្ស តាមពត៌មានវិទ្យា

មាត្រា ៤ .-

ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ ដែលត្រូវបើកអោយមន្ត្រីរាជការស៊ីវិល ត្រូវទូទាត់ និងបើកដោយគណនេយ្យករនៃរតនាគារ ដោយពុំបាច់មានអាណាប័ណ្ណជាមុនឡើយ ។ ការទូទាត់ត្រូវធ្វើឡើងដោយម៉ាស៊ីនកុំព្យូទ័រ នៅថ្នាក់កណ្តាល ដែលទ្រទ្រង់ប្រព័ន្ធគ្រប់គ្រងក្រោមការត្រួតពិនិត្យរបស់រតនាគារ ដែល អនុវត្តក្នុងឋានៈជាគណនេយ្យករសាធារណៈ ។ គណនេយ្យករសាធារណៈនេះ រ៉ាប់រងលើការត្រួតពិនិត្យ ចលនាបៀវត្សតាមរយៈលិខិតបញ្ជាក់នានា ។ បន្ទាប់មកក្រោយពីការរៀបចំនូវតារាងទូទាត់បៀវត្សរួចហើយ ត្រូវបញ្ជូននូវតារាងទូទាត់បៀវត្សទាំងនោះ ទៅតាមអង្គភាពបុគ្គលិកនីមួយៗដែលមានការពាក់ព័ន្ធ ។ អាណត្តិនិយតកម្មត្រូវធ្វើឡើងដោយអាណាប័ក ឬ ប្រធានស្ថាប័ន ដំណាលគ្នានឹងតារាងទូទាត់បៀវត្ស ព្រមទាំងមានទិដ្ឋាការរបស់អភិបាល ... ារវត្ថុផង ។ ការបើកប្រាក់ធ្វើឡើងដោយភ្នាក់ងារបើកផ្តល់ក្រោមការត្រួតពិនិត្យរបស់រតនាគារ ។

មាត្រា ៥ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវកំណត់នូវទំរង់បែបបទ និងការណែនាំអនុវត្តដោយលំអិតនូវអនុក្រឹត្យនេះ ស្តីពីនីតិវិធីសំរាប់អនុវត្តចំពោះលិខិតបទដ្ឋានឯកត្តជន ក្នុងការគ្រប់គ្រងតាមប្រភេទនីមួយៗ ។

## ជំពូក ៣
## វិធានការអន្តរកាល

**មាត្រា ៦ .-**

ក្រោយពេលបញ្ចប់ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិលរួច គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ត្រូវប្រើប្រាស់តារាងបៀវត្សថ្មី ។

**មាត្រា ៧ .-**

ក្រសួង ស្ថាប័នដែលប្រើប្រាស់តារាងបៀវត្សថ្មីតាមប្រព័ន្ធពត៌មានវិទ្យា ត្រូវស្នើសុំទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អំពីការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងការផ្លាស់ប្តូរស្ថានភាពគ្រួសារ របស់មន្ត្រីរាជការស៊ីវិលរៀងរាល់ខែ ។ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវរាយការណ៍ពីស្ថានភាពខាងលើនេះ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៨ .-**

ក្នុងរយៈពេលអន្តរកាល ដែលការប្រើប្រាស់តារាងបៀវត្សថ្មីតាមប្រព័ន្ធពត៌មានវិទ្យាមិនទាន់សំរេចជាស្ថាពរ ការប្រើប្រាស់នូវប្រព័ន្ធប្រើដោយដៃ បច្ចុប្បន្ននៅជាធរមាននៅឡើយ ។

**មាត្រា ៩ .-**

អនុក្រឹត្យនេះជំនួសអោយអនុក្រឹត្យលេខ ២០ អនក្រ .បក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ។ រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ២២២ អនក្រ.តត

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹតលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៨១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈពពិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## សំរេច

**មាត្រា ១ .**-តែងតាំងក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| -លោក លូ គីមឈុន | អគ្គនាយក ក.ស.ស | ប្រធាន |
| -បណ្ឌិត សំ សុខ | ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| -លោក ស៊ាន ទិសុទ្ធ | តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -លោក សាម ម៉ុនហេង | តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -លោក ឈុន ស៊ីរុន | តំណាង អាជ្ញាធរក្រុងព្រះសីហនុ | សមាជិក |
| -លោក ស៊ុត តារា | តំណាង ក្រសួងពាណិជ្ជកម្ម | សមាជិក |

**មាត្រា ២ .**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

# អនុក្រឹត្យ លេខ ២២៣ អនក្រ.គត
## ស្ដីពី
## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សម្ដេចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជនខ្មែរ នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង និងនៅសហរដ្ឋអាមេរិក ចំនួន ៣៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការកសាងព្រះវិហារ កុដិ សាលាឆាន់ និងសមិទ្ធផលជាច្រើនទៀតនៅក្នុងវត្តព្រះស្រិយោ ព្រមទាំងបានកសាងអណ្ដូងស្នប់ ចំនួន ១៩៦អណ្ដូង នៅតាមបណ្ដាស្រុក ក្នុងខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៩៤៧.៦០០:៣០ ដុល្លារអាមេរិក ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | ជិន សៅលាត | ចៅអធិការវត្តព្រះស្រិយោ | ទឹកប្រាក់ ៦២៣.៥០៣,៩០ USD |
| ២-ឧបាសិកា | ហាប់ អូន | | ទឹកប្រាក់ ៥០.៣៧៧,៥០ USD |
| ៣-ឧបាសិកា | ឌុក ទឿត | | ទឹកប្រាក់ ៣៦.៧០០ USD |
| ៤-ឧបាសក | រស់ ញ៉ឺន | | ទឹកប្រាក់ ៣២.៩៩០,៦២ USD |
| ៥-លោក | ឆាន់ ឃី និង អ្នកស្រី ឡាយ គា | | ទឹកប្រាក់ ១៩.១០០ USD |
| ៦-លោក | ម៉ឹង អ៊ិន | | ទឹកប្រាក់ ១៥.២០០ USD |
| ៧-លោក | ហេង ស៊ីម | | ទឹកប្រាក់ ១០.៣០០ USD |

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | សេខ សាម៉ន | | ទឹកប្រាក់ | ៨.០០០ USD |
| ២-ឧបាសក | ញ៉ី កែ | | ទឹកប្រាក់ | ៦.០០០ USD |

គ-មេដាយសិរីវឌ្ឍស្ថាបនាជាតិ :

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | សេខ លន់ | | ទឹកប្រាក់ | ៣.០០០ USD |
| ២-ឧបាសក | ឡូច លីន | | ទឹកប្រាក់ | ២.៥០០ USD |
| ៣-សមាគមជូនជីនៅអាមេរិក | | | ទឹកប្រាក់ | ២.៣១៩,៥៧ USD |
| ៤-ឧបាសក | ឡូច បូផាន់ | | ទឹកប្រាក់ | ២.០០០ USD |
| ៥-លោក | អ៊ុក អ៊ិន | | ទឹកប្រាក់ | ១.៩០០ USD |
| ៦-លោក | ឌី ញ៉ន | | ទឹកប្រាក់ | ១.៨០០ USD |
| ៧-លោក | អាំង កេង | | ទឹកប្រាក់ | ១.៦៥០ USD |
| ៨-លោក | លី ម៉ុន | និងអ្នកស្រី សុផា | ទឹកប្រាក់ | ១.៣៩៨ USD |
| ៩-លោក | ហួត ខៃ | និងអ្នកស្រី ម៉ុន ឡាយ | ទឹកប្រាក់ | ១.៣៨៦ USD |
| ១០-លោក | ង៉ែម ទី | និងអ្នកស្រី គង់ ថូគី | ទឹកប្រាក់ | ១.៣៨៦ USD |
| ១១-ព្រះតេជគុណ គឹម ផន | | ចៅអធិការវត្តធម្មការរាម | ទឹកប្រាក់ | ១.៦៦៤ USD |
| ១២-ព្រះតេជគុណ សម សក្តិសាគឹម | | វត្តគ្រីនប៊្ល | ទឹកប្រាក់ | ១.៦៦៤ USD |
| ១៣-ឧបាសក | ម៉ែន ទិត | ឧបាសិកា ស្ទាន់ ឈឿន | ទឹកប្រាក់ | ១.៦៦៤ USD |
| ១៤-លោក | នូ ឆៀង | និងអ្នកស្រី ប៉ា គឹមហួន | ទឹកប្រាក់ | ១.៦៦៤ USD |
| ១៥-លោក | ឆាន់ អ៊ិន | និងអ្នកស្រី ហេង ច័ន | ទឹកប្រាក់ | ១.៦៦៤ USD |
| ១៦-លោក | ហ៊ុន ស៊ុំ | និងអ្នកស្រី នូទ | ទឹកប្រាក់ | ១.៨៥០ USD |
| ១៧-អ្នកស្រី | កែវ បុប្ផានិព្វ | | ទឹកប្រាក់ | ១.៨៥០ USD |
| ១៨-ឧបាសក | នង នាង | ឧបាសិកា ម៉ុង ណម | ទឹកប្រាក់ | ១.៨៥០ USD |
| ១៩-លោក | ឱិត ជិន | អ្នកស្រី លាង លៀប | ទឹកប្រាក់ | ១.៨៥០ USD |
| ២០-លោក | ទ៉ាន់ ភូ | អ្នកស្រី ចម ឆប | ទឹកប្រាក់ | ១.៦៨០ USD |
| ២១-លោក | ឡាំ ម៉ុនគាត | អ្នកស្រី ផាត យ៉ែម | ទឹកប្រាក់ | ១.៦៨០ USD |
| ២២-ឧបាសក | ឆូ ម៉ៅ | ឧបាសិកា យ៉ឹយ យ៉ាង | ទឹកប្រាក់ | ១.៦៣២ USD |
| ២៣-លោក | យុន ចំរើន | អ្នកស្រី ផេង ហ៊ាង | ទឹកប្រាក់ | ១.៦៣២ USD |
| ២៤-លោក | អ៊ុយ សឿន | អ្នកស្រី ច្រែះ ថន | ទឹកប្រាក់ | ១.៦៣២ USD |
| ២៥-លោក | ព្រុំ ខ្សែប | អ្នកស្រី ឈិម យ៉ាសាធ | ទឹកប្រាក់ | ១.៦៣២ USD |
| ២៦-លោក | លី សាទ៉ាន់ | អ្នកស្រី ឌុល ធីនី | ទឹកប្រាក់ | ១.៦៣២ USD |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ២២៤ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគបច្ច័យ និងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅក្នុងបរិវេណវត្តព្រះវិហារកំបោរ ក្នុងឃុំកំពង់ហ្លួង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

**ក-មេដាយមាស ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ ផាត ភឿន | | | បច្ច័យ ចំនួន | ១២.៨១០ USD |
| ២-ឯកឧត្តម | ឆេត ខន | និងលោកជំទាវ | ទឹកប្រាក់ | ១៣.៩១០ USD |
| ៣-លោក | ម៉េង ស្រៀង | និងភរិយា | ទឹកប្រាក់ | ១២.០៨០ USD |
| ៤-ឯកឧត្តម | ខាំ ពូន កែវមុន្នី | | ទឹកប្រាក់ | ១១.២៣០ USD |

៥-លោក មូរ ណារ៉េត ទឹកប្រាក់ ១០.១៧៣ USD

៦-លោកឧត្តម លី គឹមឡុង ទឹកប្រាក់ ១០.០៨៤ USD

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក ហាក់ លី ទឹកប្រាក់ ៨.៥៥០ USD

២-លោកឧត្តម អៀង ប៉ុណ្ណាភា ទឹកប្រាក់ ៦.៣៧៣ USD

៣-លោក យឹម ស៊ីមុន្នី ទឹកប្រាក់ ៦.២៣២ USD

៤-ឧកញ៉ា ភិកា តុំ សុខែម ទឹកប្រាក់ ៥.០៩០ USD

៥-លោក គង់ មុហោ ទឹកប្រាក់ ៥.០០០ USD

គ-មេដាយ សំរិទ្ធស្ថាបនាជាតិ :

១-លោក ថោង ហុងឃុន ទឹកប្រាក់ ២.៥៥០ USD

២-លោក សាំង សារីម ទឹកប្រាក់ ១.៩៦០ USD

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា និងអាជ្ញាធរ ខេត្តក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ២២៥ អនក្រ.តត

## ស្តីពី

## ការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទដែលមានស្នាដៃល្អប្រសើរ ក្នុងការបំពេញការងារផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចមានរាយនាមខាងក្រោមនេះ

ក-មេដាយមាស ការងារ :

| | | |
|---|---|---|
| ១-ឯកឧត្តម | ឈឹម សៀកឡេង | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ |
| ២-ឯកឧត្តម | ឃឹម នៃលី | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ |
| ៣-ឯកឧត្តម | ឌី ចំរុងផល | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងជាអ្នកសំរបសំរួលគំរោងផ្លូវលំនៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី |
| ៤-ឯកឧត្តម | សួស គង់ | អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុនិងផែនការក្រសួងអភិវឌ្ឍន៍ជនបទ |
| ៥-ឯកឧត្តម | ទ្រី មេង | អគ្គនាយកបច្ចេកទេសក្រសួងអភិវឌ្ឍន៍ជនបទ និងជានាយកគំរោងផ្លូវលំនៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី |
| ៦-លោក | លី ប្រូស | ប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសហប្រតិបត្តិការណ៍ក្រសួងអភិវឌ្ឍន៍ជនបទ |

ខ-មេដាយប្រាក់ការងារ :

| | | |
|---|---|---|
| ១-លោក | ខួន សុផល | ប្រធានគ្រប់គ្រងគំរោងផ្លូវលំថ្នាក់ជាតិនៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី |
| ២-លោក | សុខ្ន សីន | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង និងជាប្រធានគ្រប់គ្រងគំរោងផ្លូវលំថ្នាក់ខេត្តនៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី |
| ៣-លោកស្រី | ចែម សាវ៉េ | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម និងជាប្រធានគ្រប់គ្រងគំរោងផ្លូវលំថ្នាក់ខេត្តនៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី |
| ៤-លោក | ម៉ី លន់ | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តស្វាយរៀង និងជាប្រធានគ្រប់គ្រងគំរោងផ្លូវលំថ្នាក់ខេត្តនៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី |
| ៥-លោក | ចាប ម៉ុច | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកណ្ដាល និងជាប្រធានគ្រប់គ្រងគំរោងផ្លូវលំថ្នាក់ខេត្តនៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី |

៦-លោក ឆរ សែន ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តតាកែវ និងជាប្រធានគ្រប់គ្រងគំរោងថ្នាក់ខេត្តនៃកម្មវិធីផលិតទាងធនាគារអភិវឌ្ឍន៍អាស៊ី

៧-លោក សេង ឆួង ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពត និងជាប្រធានគ្រប់គ្រងគំរោងថ្នាក់ខេត្តនៃកម្មវិធីផលិតទាងធនាគារអភិវឌ្ឍន៍អាស៊ី

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ២២៦ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលក្រុងព្រះសីហនុ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៣រូប ដែលបានបរិច្ចាគ ធនធានចូលរួម ជួយកសាងវត្តឧត្តមវិញ្ញាណរាម ក្នុងសង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ចំណោយ

អស់ទឹកប្រាក់ ចំនួន ៥១.៣៩៣ ដុល្លារអាមេរិក , ១៦១.៣៥០ បាតថៃ និង ៥.៦៥៥.១០០រៀល ដូចមានរាយនាមខាងក្រោមនេះ ៖

១-អកឧត្តមឧត្តមនាវីទោ ឡៅ ទិញ

២-លោកជំទាវ គាន់ ចន្ថា ឡៅទិញ

៣-លោក ម៉ុង ច័ន្ទថន

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២២៧ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី OSANAI MIEKO ប្រធានអង្គការ JHP ដែលបានជួយកសាងអាគារសិក្សាមួយខ្នង មាន០៥បន្ទប់ នៅសាលាបឋមសិក្សាអង្គម៉ាក់ព្រាង ក្នុងស្រុកជងទង់ ខេត្តកំពត ចំណាយអស់ទឹកប្រាក់ ចំនួន ២៥.០០០ ដុល្លារអាមេរិក ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

# អនុក្រឹត្យ លេខ ២២៨ អនក្រ.តត

## ស្តីពី

## ការជូនមេដាយមុនីសារាភ័ណ្ឌ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយថិបឌិនថៈ សារាភ័ណ្ឌ ជូនថ្នាក់ដឹកនាំអង្គការ " មនុស្សលោកថ្មីពិភពលោក" ០២រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការជួយគាំទ្រ និងអភិវឌ្ឍន៍វិស័យអប់រំ នៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសជួយដល់ ដេប៉ាតឺម៉ង់ ពេទ្យវិជ្ជា មនុស្សវិជ្ជា និង ប្រវត្តិវិទ្យា នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយបានបរិច្ចាគឥតសំចៃនូវកំលាំងកាយចិត្ត ចំណេះដឹង និងថវិកា មានចំនួនទឹកប្រាក់សរុបប្រមាណ ១.៥០០.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :

១-លោក CAGNASSO FRANCO ប្រធានអង្គការ

២-លោក VENDRAMIN TONI នាយកអង្គការប្រចាំព្រះរាជាណាចក្រកម្ពុជា

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

**អនុក្រឹត្យ លេខ ២២៩ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយមុនីសារាភ័ណ្ឌ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយធិបឌិន្ទមុនីសារាភ័ណ្ឌ** ជូនលោកបណ្ឌិត សម្តេច សែនគុន អ្នកឯកទេសការងារអប់រំ របស់អង្គការ អ៊ុយណេស្កូ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការជួយស្តារ និងអភិវឌ្ឍន៍ វិស័យអប់រំ នៅកម្ពុជា ជាពិសេសការងារអប់រំក្រៅប្រព័ន្ធ ដោយបានបរិច្ចាគឥតសំចៃនូវកំលាំងកាយចិត្ត ចំណេះដឹង និងសំភារៈ មានតំលៃជាទឹកប្រាក់ប្រមាណ ៥០០.០០០ ដុល្លារអាមេរិក ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ហ៊ុន សែន

★★★

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៥៥ សសរ
### ស្តីពី
### ការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមក្នុងសម័យប្រជុំពិសេស នៃមហាសន្និបាតអង្គការសហប្រជាជាតិ លើកទី២៥ ស្តីពីកិច្ចប្រជុំកំពូលពិភពលោក ដើម្បីការអភិវឌ្ឍន៍សង្គម នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស ចាប់ពីថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ហ៊ុន សែន

# III- ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

## សារាចរណែនាំ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០

## សារាចរណែនាំ លេខ ០០៣ សរណន.សក

## ស្តីពីការងារគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក

* * *

យោង :-អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

- ប្រកាសអន្តរក្រសួងលេខ ៨៥២ ប្រក.សាក.សហវ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៥ ស្តីពីការកំណត់ថ្លៃសេវាប័ណ្ណសំគាល់ផ្លាកលេខ ប័ណ្ណបើកបរ ច្បាប់អនុញ្ញាតធ្វើអាជីវកម្មត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ជលយាន ជលយានយន្ត និង សាឡាងគ្រប់ប្រភេទ ។
- សេចក្តីប្រកាសលេខ ៤០៣ ប្រក.សាក.បធ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ។

ដើម្បីគ្រប់គ្រងជលយានគ្រប់ប្រភេទតាមផ្លូវទឹកក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានល្អ និងធានាសុវត្ថិភាព ផាសុកភាព សន្តិសុខអនាម័យ សណ្តាប់ធ្នាប់ចរាចរ និងការពារគ្រោះថ្នាក់អាយុជីវិតដល់នាវិក អ្នកដំណើរ អ្នកទេសចរណ៍ ទ្រព្យសម្បត្តិមធ្យោបាយដឹកជញ្ជូន និងការពារបរិស្ថានអោយបានល្អ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំដូចតទៅ ៖

## ជំពូក ១

## អំពីប័ណ្ណសំគាល់ជលយាន

### I-ការផ្តល់ប័ណ្ណសំគាល់ជលយាន :

ជលយានគ្រប់ប្រភេទដែលធ្វើចរាចរតាមផ្លូវទឹក នៃព្រះរាជាណាចក្រកម្ពុជា មានទម្ងន់ផ្ទុកចាប់ពី ៥០០ គក្រ ឡើងទៅ រួមមានជលយានដឹកទំនិញ ដឹកប្រេងឥន្ធនៈ អ្នកដំណើរ ទេសចរណ៍ នេសាទ ជម្លង នាវាបូមដី ត្រួតខ្សាច់ គ្រឿងស្ទូច ពោះបណ្តោរ សាពេញាង ឡូងបុត (អូប៊ែរ) សាឡាង ប៉ុងតុង ទូក ផ្ទះបណ្តែតទឹក និងជលយានសណ្តោងជាកម្មសិទ្ធិរបស់រដ្ឋ របស់ឯកជន ឬរបស់ជនបរទេសដែលមានការអនុញ្ញាតត្រឹមត្រូវអោយស្នាក់នៅបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍ ត្រូវមានប័ណ្ណសំគាល់ជលយានដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

១-អគ្គនាយកដ្ឋានដឹកជញ្ជូន (នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក)

ក- ផលយានដឹកទំនិញគ្រប់ប្រភេទ ដែលមានទម្ងន់ផ្ទុកចាប់ពី ៥០តោន ឡើងទៅ ឬក៏កំលាំងម៉ាស៊ីនចាប់ពី ៩០សេះឡើងទៅ

ខ- ផលយានដឹកប្រេងឥន្ធនៈគ្រប់ប្រភេទ

គ- ផលយានដឹកអ្នកដំណើរ ចាប់ពី ៥០កន្លែង ឡើងទៅ

ឃ- ផលយានដឹកអ្នកទេសចរណ៍គ្រប់ប្រភេទ

ង- ផលយាន ផ្ទះស្នងរថយន្ត

ច- ផលយានគ្រប់ប្រភេទដែលធ្វើអាជីវកម្មឆ្លងកាត់ពីខេត្ត-ក្រុងមួយទៅខេត្ត-ក្រុងមួយទៀត

ឆ- ផលយានសណ្តោងចាប់ពី ៩០សេះឡើងទៅ

ជ- ផលយាននេសាទគ្រប់ប្រភេទ

ឈ- ផលយានគ្រប់ប្រភេទដែលធ្វើអាជីវកម្មឆ្លងដែន

ញ- ផលយានគ្រប់ប្រភេទរបស់ជនបរទេស ដែលមានការអនុញ្ញាតត្រឹមត្រូវអោយស្នាក់នៅជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា

ដ- ឡានបុត (អូប៊ីរ) ដោយមិនគិតកំលាំងសេះ

២-មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត-ក្រុង

ក- ផលយានដឹកទំនិញគ្រប់ប្រភេទ ដែលមានទម្ងន់ផ្ទុកក្រោម ៥០តោន ចុះឬក៏កំលាំងម៉ាស៊ីន ក្រោម ៩០សេះ ចុះ

ខ- ផលយានដឹកអ្នកដំណើរក្រោម ៥០កន្លែងចុះ

ផលយានយោធា ឬ នគរបាលជាតិដែលជាកម្មសិទ្ធិរបស់ក្រសួងការពារជាតិ ឬ ក្រសួងមហាផ្ទៃ ត្រូវមានប័ណ្ណសំគាល់ ចេញដោយរសាមីក្រសួងផ្ទាល់ ។

II- ការដាក់ពាក្យសុំប័ណ្ណសំគាល់ផលយាន :

ម្ចាស់ផលយានត្រូវដាក់ពាក្យសុំប័ណ្ណសំគាល់ផលយានតាមទីកន្លែង និងតាមរយៈពេលដូចខាងក្រោម :

១-នៅអគ្គនាយកដ្ឋានដឹកជញ្ជូន (នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក)

ក- ក្នុងរយៈពេលយ៉ាងយូរ ១ខែ ចំពោះផលយានមានអាស័យដ្ឋាននៅក្នុងរាជធានីភ្នំពេញ និងរយៈពេលយ៉ាងយូរ២ខែ ចំពោះផលយានមានអាស័យដ្ឋាននៅខេត្ត-ក្រុង គិតចាប់ពីថ្ងៃដែលផលយានបានសាងសង់ហើយដាក់ចុះក្នុងទឹករួច ។

ខ- ក្នុងរយៈពេលយ៉ាងយូរ ២ខែ គិតចាប់តាំងពីថ្ងៃដែលបានបង់ពន្ធគយចំពោះផលយាន ដែលនាំចូលពីប្រទេសក្រៅ ។

២-នៅមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង

ក- ក្នុងរយៈពេលយ៉ាងយូរ ១ខែ ចំពោះជលយានមានអាស័យដ្ឋាននៅក្នុងខេត្ត-ក្រុង របស់ខ្លួន និងក្នុងរយៈពេល២ខែ ចំពោះជលយានដែលនាំចូលពីខេត្ត-ក្រុងដទៃទៀត គិតចាប់តាំងពីថ្ងៃដែលជលយានបានសាងសង់រើរួចរាល់ក្នុងទីកន្លែង ឬគិតចាប់តាំងពីថ្ងៃធ្វើលិខិតលក់រួច ។

ខ- ក្នុងរយៈពេលយ៉ាងយូរ ៣ខែ គិតចាប់តាំងពីថ្ងៃដែលបានបង់ពន្ធគយ ចំពោះជលយានដែលបាននាំចូលពីប្រទេសក្រៅ ។

III- សំណុំលិខិតសុំប័ណ្ណសំគាល់ជលយាន :

ការដាក់ពាក្យសុំប័ណ្ណសំគាល់ជលយាន ត្រូវមានសំណុំឯកសារ ដូចខាងក្រោម :

១- ពាក្យសុំប័ណ្ណសំគាល់ជលយានមួយសន្លឹក ដែលមានបិទតែមត្រឹមត្រូវ ។

២- លិខិតទិញលក់មួយសន្លឹក ដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ។

៣- លិខិតបញ្ជាក់ទីលំនៅរបស់អ្នកសុំប័ណ្ណមួយសន្លឹក ឬអត្តសញ្ញាណប័ណ្ណ ប័ណ្ណគ្រួសារ ថតចម្លង មួយសន្លឹក ។

៤- បើសិនជាអ្នកស្នើសុំប័ណ្ណជាអ្នករាជការ ត្រូវមានលិខិតពីប្រធានរដ្ឋបាលមួយសន្លឹកបញ្ជាក់ថា ជលយាននេះពុំមែនជារបស់រដ្ឋ ។

៥- ប្រសិនបើជលយានជាកម្មសិទ្ធិរបស់អង្គភាពរដ្ឋ ត្រូវមានលិខិតបញ្ជាក់របស់ប្រធាននៃអង្គភាព នោះមួយសន្លឹក ។

៦- ជលយាននាំចូលត្រូវមានបង្កាន់ដៃពន្ធនាំចូលត្រឹមត្រូវ មួយសន្លឹក ។

៧- ជលយានកសាងកែច្នៃត្រូវមានលិខិតបញ្ជាក់ពីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង មួយសន្លឹក ។

៨- ប្លង់កសាងសង់ជលយានមួយសន្លឹក ដែលអនុញ្ញាតដោយក្រសួងសាធារណការនិងដឹកជញ្ជូន ។

៩- សៀវភៅប្រវត្តិជលយានមួយក្បាល ដែលមានបញ្ជាក់ពីប្រធានការដ្ឋាន ។

IV-ការបែងចែកចង្កោមលេខ និង អក្សរដើមនៃផ្លាកលេខ ឈ្មោះជលយាន :

១-អំពីចង្កោមជលយាន :

លេខសំគាល់ជលយានគ្រប់ប្រភេទ ដែលធ្វើចរាចរនៅលើផ្លូវទឹកនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបែងចែកតាមចង្កោមដូចខាងក្រោម :

- ចង្កោមលេខ ១ : ជលយានដឹកទំនិញស្ងួត
- ចង្កោមលេខ ២ : ជលយានដឹកអ្នកដំណើរ
- ចង្កោមលេខ ៣ : ជលយានដឹកប្រេងឥន្ធនៈ
- ចង្កោមលេខ ៤ : ជលយានសណ្តោង
- ចង្កោមលេខ ៥ : ជលយានគ្មានម៉ាស៊ីន

- ចង្កោមលេខ ៦ : យានយន្ត ៨ ចម្លងតាក្ស៊ី ឬមជី ត្រូលឡេរ៉ាត់ ពោះបញ្ចាល និងស្រាប់ ស្លូច
- ចង្កោមលេខ ៧ : យានយន្តបំពីមុខជំនាញ ឬ ប្រើប្រាស់ផ្ទាល់ខ្លួន
- ចង្កោមលេខ ៨ : យានយន្តនេគាទ
- ចង្កោមលេខ ៩ : យានយន្តរបស់ជនបរទេស
- ចង្កោមលេខ ១០ : យានយន្តទេសចរណ៍ និង ឡូអាប៊ុត (ជួល)
- ចង្កោមលេខ ១១ : យានយន្តសង្គ្រោះ

**២-អំពីអក្សរដើម :**

អក្សរដើមនៃផ្លាកលេខសំគាល់យានយន្តគ្រប់ប្រភេទ នៅរាជធានីភ្នំពេញ ឬខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដូចខាងក្រោម :

- រាជធានីភ្នំពេញ ........................................ ភព
- កណ្ដាល ........................................ កណ
- សៀមរាប ........................................ សរ
- បាត់ដំបង ........................................ បប
- ពោធិ៍សាត់ ........................................ ពស
- កំពង់ឆ្នាំង ........................................ កឆ
- កំពង់ធំ ........................................ កធ
- កំពង់ចាម ........................................ កច
- ក្រចេះ ........................................ ក្រច
- ស្ទឹងត្រែង ........................................ សត
- ព្រៃវែង ........................................ ពវ

៣-តារាងបែងចែកលេខយានយន្តដែលធ្វើចរាចរនៅលើផ្លូវទឹកនៃព្រះរាជាណាចក្រកម្ពុជា

| លរ | ឈ្មោះខេត្ត-ក្រុង | លេខដើម | លេខចុង | ចំនួនសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ខេត្ត កំពង់ឆ្នាំង | ២៥០១ | ៣០០០ | ៥០០ | |
| ២ | ខេត្ត កំពង់ធំ | ៣០០១ | ៣៥០០ | ៥០០ | |
| ៣ | ខេត្ត កំពង់ចាម | ៣៥០១ | ៤០០០ | ៥០០ | |
| ៤ | ខេត្ត ក្រចេះ | ៤០០១ | ៤៥០០ | ៥០០ | |
| ៥ | ខេត្ត ស្ទឹងត្រែង | ៤៥០១ | ៥០០០ | ៥០០ | |

| | | | | | |
|---|---|---|---|---|---|
| ៦ | ខេត្ត បាត់ដំបង | ៥០០១ | ៥៥០០ | ៥០០ | |
| ៧ | ខេត្ត សៀមរាប | ៥៥០១ | ៦០០០ | ៥០០ | |
| ៨ | ខេត្ត ពោធិសាត់ | ៦០០១ | ៦៥០០ | ៥០០ | |
| ៩ | ខេត្ត ព្រៃវែង | ៦៥០១ | ៧០០០ | ៥០០ | |
| ១០ | ខេត្ត កណ្ដាល | ៧០០១ | ៧៥០០ | ៥០០ | |
| ១១ | រាជធានីភ្នំពេញ | ៧៥០១ | ៨០០០ | ៥០០ | |
| ១២ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ៨០០១ | ៩០០០ | ១០០០ | |

ឧទាហរណ៍ :

ក-រាជធានីភ្នំពេញ

-ជលយានដឹកទំនិញស្ងួត ភព១ ៧៥០១

-ជលយានដឹកអ្នកដំណើរ ភព២ ៧៥០១

-ជលយានកំសាន្ដ ភព៤ ៧៥០១

ខ-ខេត្តកណ្ដាល

-ជលយានដឹកទំនិញស្ងួត កណ១ ៧០០១

-ជលយានដឹកអ្នកដំណើរ កណ២ ៧០០១

-ជលយានកំសាន្ដ កណ៤ ៧០០១

៤-ទំហំអក្សរ និងលេខ :

ផ្លាកលេខជលយានត្រូវដាក់សងខាងផ្នែកខាងក្រោម នៃជញ្ជាំងខាងមុខ មានកំពស់ពីគែមទឹកចំនួន ០.២០ ម ។ លេខនិងអក្សរសំគាល់ជលយានត្រូវសរសេរពណ៌ខ្មៅ នៅលើផ្លាកជញ្ជាំងដែលលាបពណ៌ស ។

-កំពស់ ២៤ សម -កំរាស់ ៤សម

-ទទឹង ១២ សម -ចន្លោះ ៣.៥សម

៥-រូបភាពផ្លាកលេខ :

លេខរបស់ជលយានត្រូវសរសេរជាប់នឹងជញ្ជាំងដែលលាបពណ៌ស ឧទាហរណ៍ ភព២-៨០០៤ ។ ចំពោះជលយានដែលធ្វើអាជីវកម្មផ្លូវទឹក ឆ្លងកាត់ព្រំដែនជាប្រក្រតី អក្សរ ភព ត្រូវជំនួសដោយអក្សរ PP និងមានអក្សរ HF នៅខាងចុងលេខទៀត PP1 – 8001 HF។

៦-ផ្លាកទិសដៅ :

ជលយានដឹកជញ្ជូនអ្នកដំណើរ ត្រូវមានផ្លាកទិសដៅ នៅសងខាងជលយានជាន់ទី១ ផ្នែកខាងមុខ ទល់មុខនឹងបន្ទប់អ្នកបើកបរ ។

★ នៅក្នុងផ្លាកទិសដៅនេះត្រូវសរសេរ :

-ប្រភេទជលយាន " ដឹកអ្នកដំណើរ"

-ទិសដៅ " ភ្នំពេញ កំពង់ចាម ឬ ភ្នំពេញ ក្រចេះ "

-ចំនួនអ្នកដំណើរ

-ចំនួនអ្នកទេសចរណ៍

-ទម្ងន់សរុប

ផ្លាកទិសដៅនេះត្រូវមានទំហំទៅតាមប្រភេទជលយានដូចខាងក្រោម :

ក-ជលយានដែលមានបណ្តោយពី ៣០ម ឡើងទៅ ផ្លាកទិសដៅត្រូវមានទំហំបណ្តោយ ២,២០ម និង ទទឹង ១,១០ម ។

ខ-ជលយានដែលមានបណ្តោយពី ១៥ម ទៅដល់ ២៩ម ត្រូវមានផ្លាកទិសដៅដែលមានទំហំបណ្តោយ ១,២០ម និង ទទឹង ០,៧០ម ។

ចំពោះជលយាន របស់សហគ្រាសធ្វើអាជីវកម្មដឹកជញ្ជូនជាសាធារណៈ ផ្លាកត្រូវលាបពណ៌ស អក្សរ និងលេខ ពណ៌ខ្មៅ ។

ចំពោះជលយានដឹកជញ្ជូនទំនិញផ្ទាល់ខ្លួន ផ្លាកទិសដៅត្រូវលាបពណ៌ខ្មៅ អក្សរ និងលេខពណ៌ស ។

៧-<u>អំពីឈ្មោះជលយាន</u> :

ក-ឈ្មោះជលយាន គឺអាស្រ័យដោយម្ចាស់ជាអ្នកដាក់ និងត្រូវមានការឯកភាពពីស្ថាប័នគ្រប់គ្រងសំបុត្រគល់បណ្ណសំគាល់ ។

ខ-នៅក្នុងតំបន់ធ្វើអាជីវកម្មតែមួយ ឈ្មោះជលយានមិនត្រូវអោយដូចគ្នាឡើយ ។ លើកលែងតែជលយានជាកម្មសិទ្ធិរបស់ម្ចាស់តែមួយ ប៉ុន្តែត្រូវចុះលេខរៀងនៅពីក្រោយឈ្មោះនោះ ។

<u>ឧទាហរណ៍</u> : សេរីមាសទី១ សេរីមាសទី២ ផ្កាយព្រឹកទី១ ផ្កាយព្រឹកទី២ ។ល។

គ-ឈ្មោះជលយានត្រូវសរសេរពណ៌ខ្មៅ ស្ថិតពីលើផ្លាកលេខ ចំពាក់កណ្តាលផ្ទាំងពណ៌ស ។

## ជំពូក II

## ការផ្ទេរកម្មសិទ្ធិជលយាន " កាត់ឈ្មោះ "

រាល់ការផ្លាស់ប្តូរម្ចាស់គ្រប់គ្រងជលយាន ចាំបាច់ត្រូវមានការផ្ទេរកម្មសិទ្ធិ "កាត់ឈ្មោះ" ដើម្បីអោយពេញលក្ខណៈច្បាប់ ។ ជលយានណាដែលបានប្តូរម្ចាស់គ្រប់គ្រង ហើយពុំបានធ្វើការផ្ទេរកម្មសិទ្ធិមកម្ចាស់ថ្មីទេ ការទទួលខុសត្រូវចំពោះមុខច្បាប់លើការគ្រប់គ្រងជលយាននោះ ត្រូវស្ថិតនៅលើម្ចាស់ដើមដដែល ។

**I- ទីកន្លែងធ្វើការផ្ទេរកម្មសិទ្ធិ :**

ម្ចាស់ថ្មីនៃជលយានត្រូវធ្វើការផ្ទេរកម្មសិទ្ធិជលយានទៅតាមស្ថាប័ន ដូចដែលមានចែងនៅក្នុងជំពូកទីI-1 និង I-2 ស្តីពីការសុំប័ណ្ណសំគាល់ជលយានអ្នកលក់ និងអ្នកទិញត្រូវមកផ្តិតមេដៃចំពោះមុខស្ថាប័នមានសមត្ថកិច្ច ។

ក្នុងករណីនៃការផ្ទេរកម្មសិទ្ធិជលយាននេះ ស្ថិតនៅក្នុងក្របខ័ណ្ឌអគ្គនាយកដ្ឋានដឹកជញ្ជូន (ក្នុងជំពូកទី I-1) មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ត្រូវបញ្ជាក់ពីភាពត្រឹមត្រូវនៃការលក់ទិញនេះ ហើយបើចាំបាច់ត្រូវបញ្ជូនឯកសារពាក់ព័ន្ធទាំងអស់ តាមរយៈមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ដើម្បីអគ្គនាយកដ្ឋានដឹកជញ្ជូន នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹកធ្វើការសំរេចផ្ទេរជូន ។

**II- សំណុំលិខិតសុំផ្ទេរកម្មសិទ្ធិ :**

ពាក្យសុំផ្ទេរកម្មសិទ្ធិ ត្រូវមានសំណុំលិខិតដូចខាងក្រោម :

១- ពាក្យសុំផ្ទេរកម្មសិទ្ធិ មួយសន្លឹក ដែលមានបិទតែមត្រឹមត្រូវ

២- ប័ណ្ណសំគាល់ជលយាន មួយសន្លឹក "ច្បាប់ដើម"

៣- លិខិតលក់ទិញមានអាសយដ្ឋានអ្នកលក់ និងអ្នកទិញត្រឹមត្រូវមួយសន្លឹកដែលមានបញ្ជាក់ ពីអាជ្ញាធរមូលដ្ឋាន

៤- អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណគ្រួសារមួយសន្លឹក (ថតចំលង)

**III- រយៈពេលធ្វើការផ្ទេរកម្មសិទ្ធិ :**

ការផ្ទេរកម្មសិទ្ធិ ត្រូវធ្វើអោយហើយស្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃដែលអ្នកលក់ និងអ្នកទិញបានធ្វើប្រកាសលក់ទិញ និងប្រថាប់ត្រាពន្ធដាររួច ។

**IV- ការប្តូរម៉ាស៊ីនជលយាន និង ការកែច្នៃមាឌ :**

ក្នុងករណីដែលម្ចាស់ជលយានបានប្តូរម៉ាស៊ីនជលយាន និងកែច្នៃមាឌ ត្រូវដាក់ពាក្យសុំប្តូរប័ណ្ណសំគាល់ជលយានថ្មីដែលមានបិទតែមត្រឹមត្រូវ ។ ក្នុងករណីនេះ ផ្លាកលេខត្រូវរក្សាទុកដដែល ដោយគ្រាន់តែធ្វើការកែតម្រូវក្នុងបញ្ជីគ្រប់គ្រងជលយានតែប៉ុណ្ណោះ ។ ម៉ាស៊ីនជលយាន ឬ កែច្នៃមាឌត្រូវសំរេចទៅតាមសមត្ថកិច្ចដូចមានចែងក្នុងជំពូកទីI-1 និង I-2 ។

## ជំពូក III
## ប័ណ្ណបើកបរជលយាន និង ប័ណ្ណយន្តការី

**I-ប័ណ្ណបើកបរជលយានមានបីប្រភេទ :**

១-ប័ណ្ណបើកបរជលយានថ្នាក់លេខ១ : អ្នកមានប័ណ្ណបើកបរថ្នាក់លេខ១ អាចបើកបរជលយាន ដែលមានទម្ងន់ផ្ទុកចាប់ពី ៣០១ តោន ឬ ជលយានសណ្តោងដែលមានសមត្ថភាពអូសចាប់ពី ៣០១តោនឡើងទៅ និងត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ ។

២-ប័ណ្ណបើកបរជលយានថ្នាក់លេខ២ : អ្នកមានប័ណ្ណបើកបរថ្នាក់លេខ២ អាចបើកបរជលយាន ដែលមានចំណុះផ្ទុកចាប់ពី ៥១តោន ទៅ ៣០០តោន ឬជលយានសណ្តោងដែលមានសមត្ថភាពអូស ចាប់ពី ៥១តោន ទៅ៣០០តោន និងត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ ។

៣-ប័ណ្ណបើកបរជលយានថ្នាក់លេខ៣ : អ្នកមានប័ណ្ណបើកបរថ្នាក់ លេខ៣ អាចបើកបរជលយាន ដែលមានចំណុះផ្ទុកចាប់ពី ៥០ តោន ចុះក្រោម និងត្រូវមានអាយុយ៉ាងតិច ២២ឆ្នាំ ។

**II- ប័ណ្ណយន្តការី :**

នៅតាមជលយានគ្រប់ប្រភេទ ត្រូវមានយន្តការីម្នាក់ដែលមានភារកិច្ចទទួលខុសត្រូវលើផ្នែកម៉ាស៊ីន ។ យន្តការីម្នាក់ៗ ត្រូវមានប័ណ្ណយន្តការីជាប់នឹងខ្លួន ។

ប័ណ្ណយន្តការីមានបីប្រភេទ :

១- ប័ណ្ណយន្តការីថ្នាក់លេខ១ អ្នកមានប័ណ្ណយន្តការីថ្នាក់លេខ១ ត្រូវនៅប្រចាំការនៅលើជលយាន ដែលមានកំលាំងម៉ាស៊ីនពី ១៥១ សេះឡើងទៅ និងត្រូវមានអាយុយ៉ាងតិច ២២ ឆ្នាំ ។

២- ប័ណ្ណយន្តការីថ្នាក់លេខ២ អ្នកមានប័ណ្ណយន្តការីថ្នាក់លេខ២ ត្រូវនៅប្រចាំការក្នុងជលយាន ដែលមានកំលាំងម៉ាស៊ីនពី ៩១ សេះដល់ ១៥០សេះ និងត្រូវមានអាយុយ៉ាងតិច ២២ ឆ្នាំ ។

៣- ប័ណ្ណយន្តការីថ្នាក់លេខ៣ អ្នកមានប័ណ្ណយន្តការីថ្នាក់លេខ៣ ត្រូវនៅប្រចាំការក្នុងជលយាន ដែលមានកំលាំងម៉ាស៊ីនពី ៣០ សេះ ដល់ ៩០សេះ និងត្រូវមានអាយុយ៉ាងតិច ២០ ឆ្នាំ ។

**III- ស្ថាប័នចេញប័ណ្ណបើកបរជលយាន និង បណ្ណយន្តការី :**

ជលយានគ្រប់ប្រភេទដែលមានកំលាំង ម៉ាស៊ីនចាប់ពី ១៥សេះ ឡើងទៅត្រូវមានបរិបាល ម្នាក់ ឬ អ្នកបើកបរម្នាក់ និងយន្តការីម្នាក់ ។ បរិបាលជលយាន និងយន្តការីត្រូវមានប័ណ្ណបើកបរ និងប័ណ្ណយន្តការី ។

ប័ណ្ណបើកបរជលយានថ្នាក់លេខ១ ថ្នាក់លេខ២ និង ថ្នាក់លេខ៣ ប័ណ្ណយន្តការីថ្នាក់លេខ១ ថ្នាក់លេខ២ និងថ្នាក់លេខ៣ ត្រូវចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន (នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ) ។

## IV- ពាក្យសុំប្រលងយកប័ណ្ណបើកបរ និងប័ណ្ណយន្តការី :

បេក្ខជនដែលមានបំណងប្រឡងយកប័ណ្ណបើកបរជលយាន ឬប័ណ្ណយន្តការី ត្រូវដាក់ពាក្យសុំប្រឡងដែលមានភ្ជាប់លិខិតដូចមានខាងក្រោម :

១-ពាក្យសុំប្រឡងមួយច្បាប់ ដែលមានបិទតែមត្រឹមត្រូវ

២-លិខិតពិនិត្យសុខភាពមួយច្បាប់ ចេញដោយមន្ទីរពេទ្យណាមួយដែលកំណត់ដោយក្រសួងសុខាភិបាល

៣-រូបថត ៣ គុណ ៤ ពីរសន្លឹក

៤-បង្កាន់ដៃបង់ប្រឡងមួយសន្លឹក

៥-លិខិតបញ្ជាក់សមត្ថភាពពីម្ចាស់ជលយាន និងអាជ្ញាធរដែនមួយច្បាប់

៦-លិខិតបញ្ជាក់ការសិក្សារបស់សាលាមួយច្បាប់ (បើមាន)

## V- គណៈកម្មការប្រលងយកប័ណ្ណបើកបរ ប័ណ្ណយន្តការី និងមុខវិជ្ជាដែលត្រូវប្រលង :

១-<u>គណៈកម្មការប្រលង</u>

ការប្រឡងយកប័ណ្ណបើកបរជលយាន ឬ ប័ណ្ណយន្តការី ត្រូវធ្វើនៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក និងត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់គណៈកម្មការមួយដែលតែងតាំងឡើងដោយអគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ។

២-<u>មុខវិជ្ជាប្រលង</u> :

មុខវិជ្ជាប្រលងយកប័ណ្ណបើកបរជលយាន និង ប័ណ្ណយន្តការីមាន :

ក-ប័ណ្ណបើកបរជលយាន

ច្បាប់ចរាចរផ្លូវទឹក ក្នុងនោះមានការសួរផ្ទាល់មាត់ ការអនុវត្តន៏ជាក់ស្តែង និងវិធានការសង្គ្រោះ

ខ-ប័ណ្ណយន្តការី :

-ចំណេះដឹងខាងយន្តសាស្ត្រ និងការថែទាំម៉ាស៊ីន

-ច្បាប់ចរាចរផ្លូវទឹក (ផ្នែកឲ្យស្លឹដោយសួរផ្ទាល់មាត់)

-លិខិតបញ្ជាក់ពីសាលាបង្រៀនជួសជុលម៉ាស៊ីនគ្រឿងយន្តគ្រប់ប្រភេទ

## VI- ការប្រគល់ប័ណ្ណបើកបរជលយាន ឬប័ណ្ណយន្តការី :

១-បេក្ខជនដែលប្រឡងជាប់ត្រូវយកប័ណ្ណបើកបរជលយាន ឬប័ណ្ណយន្តការី នៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ក្រសួងសាធារណការ និងដឹកជញ្ជូន ។ នាយកដ្ឋានដឹកជញ្ជូន ផ្លូវទឹកប្រគល់ប័ណ្ណបើកបរជលយាន ឬ ប័ណ្ណយន្តការី បណ្តោះអាសន្នដែលមានប្រសិទ្ធភាពក្នុងរយៈពេល ៤៥ ថ្ងៃ ។ អ្នកកាន់ប័ណ្ណបណ្តោះអាសន្ន ត្រូវមកបើកប័ណ្ណបើកបរជលយាន ឬប័ណ្ណយន្តការីជាស្ថាពរ ក្នុងរយៈពេល ២ ឬ ៣ថ្ងៃ មុនផុតកំណត់ប្រសិទ្ធភាពប័ណ្ណបណ្តោះអាសន្ន ។

២-ក្នុងករណីដែលប័ណ្ណត្រូវបាត់បង់ដោយប្រការណាមួយ សាមីខ្លួនត្រូវប្តឹងរាយការណ៍ទៅអង្គភាពនគរបាលមូលដ្ឋានរបស់ខ្លួន រួចហើយត្រូវយកសេចក្តីប្រកាសអំពីការបាត់ប័ណ្ណដែលបញ្ជាក់ដោយអង្គភាពនគរបាលនោះមកនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ដើម្បីសុំទុតិយតាប្រើប្រាស់បន្ត ។ ប័ណ្ណបើកបរជលយាន ឬ យន្តការីដែលថតចម្លងពុំមានតំលៃក្នុងការប្រើប្រាស់ឡើយ ។ ក្នុងករណីដែលប័ណ្ណត្រូវរហែក ទក់ ឬ រលុបអក្សរ មើលមិនច្បាស់ ត្រូវស្នើសុំប្តូរប័ណ្ណថ្មី ។

៣-ចំពោះបេក្ខជនដែលប្រឡងធ្លាក់ ត្រូវដាក់ពាក្យសុំប្រឡងសាជាថ្មី នៅពេលមានការប្រកាសផ្សាយដំណឹងអំពីការប្រឡងនេះ ។

## ជំពូក IV

## ការស្លាកនា និង ជួសជុលជលយាន

### I- ការស្លាកនាជលយាន :

-ការស្លាកលេខជលយានគ្រប់ប្រភេទ ត្រូវតែច្បាប់តាមរូបភាពស្លាកប័ណ្ណគំរូដែលនៅក្នុងជំពូក I គ្រប់ចំណុច I-1 និង I-2 ដែលបានកំណត់ជូនសិទ្ធិគ្រប់គ្រង ដូចខាងលើ ។

-ម្ចាស់កាងសង់ជលយាន ត្រូវដាក់ពាក្យសុំនៅស្ថាប័នខាងលើនេះ ដោយមានសំណុំលិខិតដូចតទៅ :

១-ពាក្យសុំមួយច្បាប់ ដែលមានបិទតែមត្រឹមត្រូវ<br>
២-តំរោងប្រើប្រាស់សំភារៈ មួយច្បាប់<br>
៣-ប្លង់ជលយាន មួយច្បាប់<br>
៤-លិខិតបញ្ជាក់ទីតាំងនៅ មួយច្បាប់

-ការសំរេចលើការស្លាកនាជលយានគ្រប់ប្រភេទ ជាសិទ្ធិរបស់អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងជាសិទ្ធិរបស់ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត-ក្រុង ទៅតាមប្រភេទជលយានដែលបានរៀបរាប់នៅចំណុច I-1 និង I-2 ខាងលើ ។

-នៅពេលបានទទួលសេចក្តីអនុញ្ញាតអោយស្លាកនា នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹកត្រូវប្រគល់សៀវភៅប្រវត្តិជលយានមួយច្បាប់ទៅម្ចាស់ស្លាកនា ។ នៅពេលស្លាកនារួចរាល់ហើយ ត្រូវមានហត្ថលេខាទទួលស្គាល់របស់ប្រធានការដ្ឋាន នៃសំណង់នោះនៅលើសៀវភៅប្រវត្តិជលយាន ។

### II- ការជួសជុលជលយាន :

-ការជួសជុលជលយានគ្រប់ប្រភេទ ត្រូវមានលិខិតអនុញ្ញាត ចេញដោយនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ។

-ម្ចាស់ជលយាន ត្រូវដាក់ពាក្យសុំ ដោយមានសំណុំលិខិតដូចតទៅ :

១-ពាក្យសុំមួយច្បាប់ ដែលមានបិទតែមត្រឹមត្រូវ

២-តំរោងគំរោងសារៈជួសជុល មួយច្បាប់

៣-ប្លង់គោងគរង់ជលយាន មួយច្បាប់

៤-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស មួយច្បាប់ និងសៀវភៅប្រវត្តិជលយាន មួយក្បាល

៥-លិខិតបញ្ជាក់ទីលំនៅ មួយច្បាប់

៦-លិខិតបញ្ជាក់ទីកន្លែងជួសជុលជលយាន មួយច្បាប់

III- នៅពេលសាងសង់ ឬជួសជុលជលយានរួចហើយ ម្ចាស់ជលយានត្រូវមករាយការណ៍ ជូននាយកដ្ឋាន ដឹកជញ្ជូនផ្លូវទឹក ដើម្បីធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសឡើងវិញ ។

IV- ការបើកការដ្ឋានសាងសង់ និងជួសជុលជលយានគ្រប់ប្រភេទ ត្រូវមានច្បាប់អនុញ្ញាតពីក្រសួងសាធារណការ និងដឹកជញ្ជូន ។

-ត្រូវមានសំណុំលិខិតដូចខាងក្រោម :

១-ពាក្យសុំមួយច្បាប់ ដែលមានបិទតែមត្រឹមត្រូវ

២-ប្លង់ដីកម្មសិទ្ធិបញ្ជាក់ ដោយអាជ្ញាធរមូលដ្ឋាន

៣-ប្លង់ការដ្ឋាន មួយច្បាប់

៤-លិខិតបញ្ជាក់ទីលំនៅ មួយច្បាប់

៥-បង្កាន់ដៃពន្ធ មួយច្បាប់

## ជំពូក V

## ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន

-ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ធ្វើឡើងក្នុងគោលបំណងអោយជលយានមានលក្ខណៈបច្ចេកទេសគ្រប់គ្រាន់ ដើម្បីធានាសុវត្ថិភាព ផាសុកភាព សន្តិសុខ ចរាចរ សណ្តាប់ធ្នាប់ ចរាចរការពារខូចខាតដល់ទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជារបស់ឯកជន ព្រមទាំងអាយុជីវិតរបស់ប្រជាជន ដែលធ្វើដំណើរតាមផ្លូវទឹក ក្នុងព្រះរាជាណាចក្រកម្ពុជា ។ ជលយានត្រូវមានលក្ខណៈបច្ចេកទេស ដូចមានរៀបរាប់ក្នុងចំណុច១ ខាងក្រោមនេះ :

១-<u>លក្ខណៈបច្ចេកទេសជលយានដែលត្រូវអនុញ្ញាតអោយធ្វើអាជីវកម្ម</u> :

ក-<u>អំពីសំបកជលយាន</u> : សំបកជលយានត្រូវមានគុណភាពធានាសុវត្ថិភាពបានត្រឹមត្រូវ ទោះជាដែក ឈើ ឬ ប្លាស្ទិកក៏ដោយ ។

ខ-<u>អំពីគ្រឿងម៉ាស៊ីន</u> : ផ្នែកនីមួយៗ នៃគ្រឿងម៉ាស៊ីនត្រូវរៀបចំនៅក្នុងស្ថានភាពមួយដែលត្រូវមានដំណើរការប្រក្រតីជានិរន្តរ៍ ត្រូវមានរនាំងជាសំណាញ់ដែកបាំងជុំវិញម៉ាស៊ីន ដើម្បីការពារកុំអោយអ្នកដំណើរ ឬជនផ្សេងៗទៀតផុង ឬជ្រុលទៅប៉ះនឹងម៉ាស៊ីនដោយចៃដន្យបណ្តាលអោយមានគ្រោះថ្នាក់។

ឥ-អំពីបច្ចេកកិច្ច : កន្លែងអង្គុយរបស់អ្នកបើកបរត្រូវមានភាពទូលាយមិនចង្អៀតចង្អល់ និងត្រូវស្ថិតនៅក្នុងស្ថានភាពដែលអាចអោយអ្នកបើកបរមើលទៅខាងមុខ និងសងខាងបានច្បាស់ ។

ឈ-អំពីដំបូលជលយាន :

-ជលយានដែលមានបណ្តោយពី ២៥ ម ឡើងទៅ អាចធ្វើដំបូលពេញដល់កន្សៀជលយាន ។

-ជលយានដែលមានបណ្តោយ ២១ ម ដល់២៤ម ការធ្វើដំបូលត្រូវទុកចំហរ ៣ម ពីកន្សៀជលយាន ។

-ជលយានដែលមានបណ្តោយចាប់ពី១៨ម ដល់២០ម ការធ្វើដំបូលត្រូវទុកចំហរ ពីពាក់កណ្តាលជលយាន ដល់កន្សៀជលយាន ។

-ជលយានដែលមានបណ្តោយចាប់ពី ១៧ម ចុះក្រោម មិនត្រូវធ្វើដំបូលឡើយ ។

ឯ-អំពីស៊ីផ្លេ និងជួង : ជលយានគ្រប់ប្រភេទត្រូវមានស៊ីផ្លេសំរាប់ប្រើប្រាស់នៅពេលត្រូវការ ។ សម្លេងស៊ីផ្លេជលយានត្រូវឮសូរអោយបានចម្ងាយយ៉ាងតិចបំផុត ១.៥០០ម ។ ទន្ទឹមនឹងស៊ីផ្លេ គ្រប់ជលយានត្រូវមានជួងដែលមានមាត់ក្រោមបន្ទាត់ផ្ចិត ០,២០ម សំរាប់ប្រើប្រាស់នៅពេលអាកាសធាតុមិនល្អ និង ប្រកាសអាសន្ន ។

ច-គ្រឿងបំភ្លឺ និង សញ្ញា :

ច.១-ជលយានធំតូច ជលយានសណ្តោង

- ជលយានធំ តូច ដឹកអ្នកដំណើរ ទំនិញ ប្រេងឥន្ធនៈ ជលយានសណ្តោង ត្រូវមានភ្លើងសញ្ញាដូចខាងក្រោម :
- ចំពោះជលយានដឹកអ្នកដំណើរត្រូវមានភ្លើងពណ៌សមួយដាក់នៅតាមដងក្តោង ដែលស្ថិតនៅពាក់កណ្តាលជលយាន និងបណ្តោយអ័ក្សជលយាន និងមានកំពស់ ៣ម ពីដំបូលឡើងទៅ ។ ភ្លើងពណ៌សនេះត្រូវមើលឃើញចម្ងាយ ១.៥០០ម នៅពេលមានអាកាសធាតុល្អ និងត្រូវមានពន្លឺចាំង ២២៥ អង្សាទៅមុខ ។ ពេលថ្ងៃភ្លើងពណ៌ស ជំនួសដោយបាល់ពណ៌ខ្មៅមួយ ដែលមានបន្ទាត់ផ្ចិត ០.៣០ ម ។
- ចំពោះជលយានដឹកទំនិញត្រូវមានភ្លើងពណ៌សមួយ និងភ្លើងពណ៌ក្រហមមួយថែមទៀត ។
- ភ្លើងពណ៌ស ដាក់ពីលើភ្លើងពណ៌ក្រហម ឃ្លាតពីគ្នាចំនួន មួយម៉ែត្រ ។ ពេលថ្ងៃភ្លើងពណ៌សនេះត្រូវជំនួសដោយត្រីកោណពណ៌ស និងភ្លើងពណ៌ក្រហម ជំនួសដោយបាល់ ពណ៌ខ្មៅ ។
- ចំពោះជលយានដឹកគ្រឿងផ្ទុះ គ្រឿងឆេះ ត្រូវមានភ្លើងពណ៌ក្រហមមួយទៀតដាក់ទន្ទឹមនឹងភ្លើងពណ៌ស ដែលបានកំណត់ខាងដើមរួចហើយ ។ នៅពេលថ្ងៃភ្លើងពណ៌ក្រហមនេះ ត្រូវជំនួសដោយអក្សរ B ពណ៌ក្រហម ។

- ចំពោះជលយានគសពេញ្លងដែលមានប្រវែងតិចជាង ១០០ម ត្រូវមានភ្លើងពណ៌ស ចំនួនពីរ ឃ្លាតពីគ្នាចំនួន ១ម ពីលើមកក្រោម ។ ចំពោះជលយានគសពេញ្លងដែលមានប្រវែងលើសពី១០០ម ត្រូវមានភ្លើងពណ៌ស ចំនួន ៣ ឃ្លាតពីគ្នាចំនួន ១ម ពីលើមកក្រោម ។ នៅពេលថ្ងៃភ្លើងពណ៌ស ត្រូវជំនួសដោយពោងកងពណ៌ខ្មៅ ដែលមានបន្ទាត់ផ្ចិត ០.៣០ ម ។
- ភ្លើងបៃតងមួយនៅខាងស្តាំ និងភ្លើងក្រហមមួយនៅខាងឆ្វេង ដាក់អមសងខាងដំបូល ។ ភ្លើងពណ៌ទាំងពីរនេះ ត្រូវមើលឃើញពីចំងាយ ១០០០ម នៅពេលមានអាកាសធាតុល្អ ។ ភ្លើងពណ៌ក្រហមត្រូវចាំង ១១២អង្សា ៣០ ទៅមុខ និងនៅចំហៀងខាងឆ្វេង ។ ភ្លើងពណ៌បៃតងត្រូវចាំង ១១២អង្សា ៣០ ទៅមុខ និងនៅចំហៀងខាងស្តាំ ។ ភ្លើងពណ៌ទាំងពីរនេះ ត្រូវមានដាក់ក្បាំងដើម្បីកុំអោយមើលឃើញពីខាងក្រោយ ។
- ភ្លើងពណ៌សមួយនៅកន្ទៀជលយាន ត្រូវចាំង ១៣៥អង្សាទៅក្រោយ និងអាចមើលឃើញនៅចងាយ ១.៥០០ម ។

ច-២ ទូក សាឡង់ ដែលមានចំណុះលើសពី ២៥ តោន ត្រូវមាន :

- ភ្លើងពីរជាប់នឹងដំបូល ភ្លើងពណ៌ក្រហមនៅខាងឆ្វេង និងភ្លើងបៃតងនៅខាងស្តាំ និងមានពន្លឺមើលឃើញក្នុងចំងាយ ៩០០ម និងត្រូវចាំង ១១២អង្សា ៣០ ទៅមុខ និងទៅចំហៀងសងខាង ។
- ភ្លើងពណ៌សមួយនៅខាងកន្ទៀចាំងពន្លឺ១៣៥អង្សាទៅក្រោយ និងអាចមើលឃើញនៅចំងាយ ១.៥០០ម ។

ច-៣ ទូក សាឡង់ ដែលមានចំណុះស្មើ ឬ តិចជាង ២៥ តោន ត្រូវមាន :

- ភ្លើងពណ៌ស ភ្លឺគ្រប់ទិស កំពស់តិចបំផុតពីដំបូលទូក ឬសាឡង់ចំនួន ២ ម ។

ឆ - ឧបករណ៍ការពារសុវត្ថិភាព :

ឆ-១ អំពីពោងក្បូន ពោងកង និងពោងអាវ : ជលយានគ្រប់ប្រភេទត្រូវមានពោងក្បូន

- ពោងកង និងពោងអាវ សំរាប់ការពារនៅពេលមានគ្រោះថ្នាក់ ។
- ពោងក្បូនធុនតូចមានបន្ទាត់ផ្ចិត ០.២៥ម និងបណ្តោយ ០.៥០ម ។
- ពោងក្បូនធុនតូចមានបន្ទាត់ផ្ចិត ០.២៥ម និងបណ្តោយ ០.៦០ម ។
- ពោងក្បូនធុនធំមានបន្ទាត់ផ្ចិត ០.៣០ម បណ្តោយ ១.៣០ម ។
- ក្នុងជលយាននីមួយៗ ត្រូវមានពោងក្បូនចំនួនពី ៥ឡើងទៅ ។ ក្នុងក្បូននីមួយៗ ត្រូវមានពោង ៤ ដែលលាបពណ៌ក្រហម រីឯឃ្នាបក្បូនត្រូវលាបពណ៌ស ។

នៅមុខក្បូនត្រូវសរសេរឈ្មោះ និងលេខផលយានលើក្តារបន្ទះដែលមានទទឹង ០.១៥ម ដាក់កាត់ទទឹងមុខក្បូននេះ ។

- ឧទាហរណ៍ : សេរីមាស ភព ២-៨០០០ ។ ពោងក្បូនត្រូវដាក់នៅលើដំបូលផលយាន ដោយពុំមានចងជាប់នឹងអ្វីឡើយ ។
- ពោងកងត្រូវមានបន្ទាត់ផ្ចិតពី ០.៥០ម ទៅ ០.៨០ម និង មានកំរាស់ពី ០.១៥ម ទៅ ០.២០ម ។ ពោងកងត្រូវលាបពណ៌ក្រហម អង្កន់ពណ៌ស និងមានដាក់ឈ្មោះ និងលេខផលយាន ។
- ឧទាហរណ៍ : សេរីមាស ភព ៨.០០០ ។ ក្នុងផលយាននីមួយៗ ត្រូវមានពោងកងពី៥ឡើងទៅ ។
- ពោងអាវ : ចំពោះផលយានដឹកអ្នកដំណើរ ឬ ទេសចរណ៍ត្រូវមានពោងអាវសង្គ្រោះអោយបានគ្រប់ចំនួនអ្នកដំណើរ ។

ក-២ <u>ស្ពានឆ្លង</u> : គ្រប់សំពៅយានត្រូវមានស្ពានឆ្លងធ្វើអំពីឈើដែលមានទទឹង០.៤០ម យ៉ាងតិចសំរាប់អោយអ្នកដំណើរឆ្លងកាត់នៅពេលត្រូវការ ។

ឆ-៣ <u>ប្រដាប់ពន្លត់ភ្លើង និង ម៉ាស៊ីនបូមទឹក</u> : គ្រប់ផលយានត្រូវមានប្រដាប់ពន្លត់ភ្លើង និង ម៉ាស៊ីនបូមទឹកសំរាប់ការពារពេលមានគ្រោះថ្នាក់ភ្លើងឆេះ ឬទឹកចូលដោយចៃដន្យ ។

ឆ-៤ <u>ថ្នាំពេទ្យបំរុង និង បង្គន់អនាម័យ</u> : ផលយានដឹកអ្នកដំណើរ និង ទេសចរណ៍ត្រូវមានប្រអប់ថ្នាំពេទ្យ និងមានថ្នាំពេទ្យបំរុងមួយចំនួនសំរាប់ការពារ ចំពោះអ្នកដំណើរដែលមានការឈឺថ្កាត់ដោយចៃដន្យ ។ ម្យ៉ាងទៀតផលយានដឹកអ្នកដំណើរ និង ទេសចរណ៍ ត្រូវតែមានបង្គន់អនាម័យ និង ស្អាតជានិច្ច ។

ឆ-៥ <u>ក្រណាត់តង់ ឬ សំបកកង់រថយន្ត ឈើ ផ្លោង ខ្សែពួរ យុថ្កា</u> : គ្រប់ផលយានត្រូវមានក្រណាត់តង់ សំរាប់ការពារពេលភ្លៀង ឬ ការពារថ្ងៃក្តៅ ។ សំបកកង់រថយន្ត ឬឈើ ដាក់នៅសងខាងផលយាន ដើម្បីការពារប៉ះទង្គិច ។ ផ្លោងដោលសំរាប់ការពារនៅពេលផលយានចេញចូលផែ ឬ ច្រាំង ។ ខ្សែពួរ ខ្សែកួនតឹងនាំខ្សែពួរ និង យុថ្កា សំរាប់ប្រើប្រាស់នៅពេលផលយានចូលចតនៅផែ ឬ នៅពេលត្រូវការដោយចៃដន្យ ។

ឆ-៦ <u>ឧបករណ៍ស្នប់ទឹក</u> : ផលយានគ្រប់ប្រភេទត្រូវមានឧបករណ៍ស្នប់ទឹក ដើម្បីការពារកុំអោយកៀង ។

ក-៧ ចំណុះទំងន់ផ្ទុកចំណិញ : នៅពេលដែលចុះបញ្ជិត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានទាំងអស់ត្រូវសរសេរជំរៅស៊ីទឹកលើស្លាកជលយាន ឬ បន្ទាត់ផ្ទៃទឹកលើស្លាកជលយាន អតិបរិមាតាមការណែនាំរបស់គណៈកម្មការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ។

ក-៨ វិទ្យុទាក់ទង : រាល់ជលយានធ្វើចរាចរផ្លូវឆ្ងាយត្រូវមានវិទ្យុទាក់ទង ។

២ - ប្រភេទនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេស :

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសមានពីរប្រភេទ :

ក- ការត្រួតពិនិត្យជាកាតព្វកិច្ច គឺជាការត្រួតពិនិត្យនៅគ្រាដំបូងមុនពេលដាក់ពាក្យសុំអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន ។

ខ- ការត្រួតពិនិត្យតាមពេលកំណត់ អនុវត្តចំពោះជលយានដែលបានធ្វើអាជីវកម្មរួចហើយនឹងត្រូវមកធ្វើការត្រួតពិនិត្យតាមពេលកំណត់របស់នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

ការត្រួតពិនិត្យនេះត្រូវធ្វើក្នុងរយៈពេល ៦ខែម្តង ចំពោះជលយានសំបកឈើ និង មួយឆ្នាំម្តងចំពោះជលយានសំបកដែក ឬ ផ្លាស្ទិក ។ ក្នុងករណីពិសេសរយៈពេលនេះ ត្រូវបានបំព្រួញខ្លីជាងនេះទៀត តាមការវាយតំលៃរបស់គណៈកម្មការត្រួតពិនិត្យបច្ចេកទេស ។

គ- ការត្រួតពិនិត្យធ្មុត : ការត្រួតពិនិត្យធ្មុត គឺជាការត្រួតពិនិត្យ ដោយមិនអោយសាមីខ្លួនដឹងជាមុន ។ ការត្រួតពិនិត្យនេះមានទិសដៅធានាដល់ការគោរពច្បាប់អាជីវកម្ម និងលិខិតស្នាមផ្សេងៗ ដែលម្ចាស់ប្រើប្រាស់ជលយានត្រូវមានគ្រប់គ្រាន់តាមការកំណត់របស់រដ្ឋ ។ ការពិនិត្យធ្មុតអាចធ្វើនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែងតាមផ្លូវទឹក ។

៣ - សិទ្ធិអំណាចនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេស :

ក- ការត្រួតពិនិត្យជាកាតព្វកិច្ច និងការត្រួតពិនិត្យ តាមពេលកំណត់ :

នៅក្រសួងសាធារណការនិងដឹកជញ្ជូន ការត្រួតពិនិត្យនេះត្រូវធ្វើឡើង ដោយនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ។

- នៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ការត្រួតពិនិត្យធ្វើឡើងដោយការិយាល័យដឹកជញ្ជូនផ្លូវទឹក ។

ខ- ការពិនិត្យធ្មុត :

- នៅក្រសួង ការត្រួតពិនិត្យធ្មុតធ្វើដោយគណៈកម្មការចំរុះមួយ តែងតាំងដោយរដ្ឋមន្ត្រី អនុលោមតាមសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានតំណាង

ក្រសួងសាធារណការ និងដឹកជញ្ជូន ជាប្រធាន ។ ការត្រួតពិនិត្យច្នាក់ធ្វើឡើងនៅគ្រប់ទីកន្លែង តាមផ្លូវទឹក ក្នុងព្រះរាជាណាចក្រកម្ពុជា តាមការអញ្ជើញរបស់ប្រធាន នៅពេលណាដែលក្រសួងសាធារណការ និងដឹកជញ្ជូន យល់ឃើញថាជាការចាំបាច់ ។

- នៅតាមខេត្ត-ក្រុងនានា ការត្រួតពិនិត្យនេះត្រូវធ្វើដោយគណៈកម្មការចំរុះមួយ តែងតាំងដោយអភិបាលខេត្ត-ក្រុង ដែលមានតំណាងមន្ទីរសាធារណការ និងដឹកជញ្ជូន ជាប្រធាន ។ ការត្រួតពិនិត្យច្នាក់នេះធ្វើឡើងតែក្នុងខេត្ត-ក្រុងរបស់ខ្លួន តាមការអញ្ជើញរបស់ប្រធាន នៅពេលណាដែលមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត-ក្រុង យល់ឃើញថាជាការចាំបាច់ ។

គ- <u>កំណត់ហេតុត្រួតពិនិត្យ</u> :

- នៅពេលត្រួតពិនិត្យ គណៈកម្មការត្រូវតែធ្វើកំណត់ហេតុត្រួតពិនិត្យនិងកត់ត្រាចំណុចខ្វះខាតចូលក្នុងសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ។
- ក្នុងករណីដែលជលយានមានចំណុចខ្វះខាតធ្ងន់ធ្ងរ ត្រូវតែបង្គាប់អោយផ្អាកសកម្មភាពចរាចរជាបន្ទាន់ ។ ក្រុមចំរុះត្រូវដកហូតយកឯកសារចរាចរ ដោយចេញបណ្ណដែលបញ្ជាក់អំពីការដកហូតនេះអោយទៅម្ចាស់ជលយាន រួចកំណត់អោយម្ចាស់ជលយានជួសជុលចំណុចខ្វះខាត ហើយចូលទៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត-ក្រុង តាមរយៈដែលគណៈកម្មការចំរុះកំណត់ដើម្បីធ្វើការត្រួតពិនិត្យសាជាថ្មី ។ ឯកសារចរាចរដែលគណៈកម្មការចំរុះបានដកហូតនេះ ត្រូវយកមកប្រគល់អោយនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត-ក្រុង នៅពេលចប់បេសកកម្មត្រួតពិនិត្យម្តងៗ ។

**៤- បែបបទលិខិតស្នាមមុន និងក្រោយពេលត្រួតពិនិត្យតាមពេលកំណត់ :**

ក- ម្ចាស់ជលយានត្រូវយកឯកសារចរាចរ មកតំកល់ទុកនៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត-ក្រុងនៅថ្ងៃដែលត្រូវធ្វើការត្រួតពិនិត្យ ។ ឯកសារចរាចរមានដូចខាងក្រោម :

១- ប័ណ្ណសំគាល់ជលយាន
២- ប័ណ្ណបើកបរជលយាន
៣- សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន
៤- សៀវភៅសកម្មភាពប្រចាំថ្ងៃ
៥- ច្បាប់អនុញ្ញាតធ្វើអាជីវកម្ម

៦- សៀវភៅទិដ្ឋាការធ្វើដំណើរ

៧- បង្កាន់ដៃពន្ធ

ខ- ក្នុងករណីដែលជលយានត្រូវប្រកាសថា មានលក្ខណៈបច្ចេកទេសអាចបើកបរបាន ម្ចាស់ជលយានត្រូវសុំសំណុំលិខិតទាំង៧ នេះវិញ ។

គ- ក្នុងករណីដែលជលយានត្រូវបានប្រកាសថា ពុំមានលក្ខណៈបច្ចេកទេសគ្រប់គ្រាន់ទេនោះ ឯកសារចរាចរទាំង៧នេះ ត្រូវតំកល់ទុកជាបណ្ដោះអាសន្ន នៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្ត-ក្រុង ដែលត្រូវកំណត់ពេលអោយម្ចាស់ជលយានយកឯកសារមកធ្វើការត្រួតពិនិត្យសាជាថ្មីក្នុងរយៈពេល៧ថ្ងៃ បន្ទាប់ពីការត្រួតពិនិត្យលើកទី១ ។

ឃ- ផុតរយៈពេល៧ថ្ងៃនេះ បើសិនម្ចាស់ជលយានពុំអាចយកជលយានមកធ្វើការត្រួតពិនិត្យបានទេនោះ ម្ចាស់ជលយានត្រូវធ្វើលិខិតសុំតំកល់ឯកសារចរាចរជាលើកទី១ ។

ង- ផុតរយៈពេលតំកល់ឯកសារដែលបានសុំបន្តនៅលើកទី១ ជលយាននៅតែពុំអាចយកមកធ្វើការត្រួតពិនិត្យទៀតនោះ ត្រូវសុំបន្តការតំកល់ឯកសារជាលើកទី២ទៀត ។ រយៈពេលសុំបន្តតំកល់ឯកសារនេះ មិនត្រូវអោយលើសពី៤ខែឡើយ គិតចាប់ពីថ្ងៃដែលគណៈកម្មការបានពិនិត្យឃើញថា ជលយានមានលក្ខណៈបច្ចេកទេសពុំអាចបើកបរបាន ។ ផុតរយៈពេល ៤ខែនេះ ច្បាប់អនុញ្ញាតធ្វើអាជីវកម្ម ត្រូវទុកជាមោឃៈ ។

**៥- ការមិនគោរពកាលបរិច្ឆេទកំណត់ក្នុងការត្រួតពិនិត្យ :**

ក- ក្នុងករណីដែលម្ចាស់ជលយានពុំបានយកឯកសារចរាចរ មកតំកល់តាមកាលបរិច្ឆេទកំណត់នោះ ចាត់ទុកថាម្ចាស់ជលយានពុំបានគោរពថ្ងៃ ខែ ដែលបានកំណត់ ហើយត្រូវទទួលផាកពិន័យគិតតាមចំនួនថ្ងៃដែលយឺតយ៉ាវក្នុងការពុំបានយកឯកសារមកតំកល់ ។

ខ- ផុតរយៈពេល៧ថ្ងៃ បន្ទាប់ពីការត្រួតពិនិត្យ នៅលើកទី១ ដែលមានចែងនៅត្រង់ចំណុច "៤គ" ម្ចាស់ជលយានពុំបានយកជលយានមកពិនិត្យសាជាថ្មី ហើយពុំបានដាក់ពាក្យសុំតំកល់ឯកសារចរាចរនោះ ជលយាននេះត្រូវចាត់ទុកថាមានការយឺតយ៉ាវក្នុងការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ។

គ- ផុតរយៈពេលដែលបានស្នើសុំបន្តនៅលើកទី១ ហើយជលយាននៅតែពុំបានយកមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសទៀត និងពុំបានសុំបន្តជាលើកទី២ទេនោះ ជលយាននេះត្រូវចាត់ទុកជាមានការយឺតយ៉ាវ ក្នុងការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ។

ឃ- ផុតរយៈពេល៤ខែ ដែលម្ចាស់ជលយានបានសុំពន្យារពេលជាបន្តបន្ទាប់ គិតចាប់តាំងពីថ្ងៃដែលគណៈកម្មការបានពិនិត្យឃើញថា ជលយានពុំមានលក្ខណៈបច្ចេកទេស អាចអនុញ្ញាតអោយធ្វើការដឹកជញ្ជូនបាន ជលយាននៅតែពុំអាចមកធ្វើការត្រួតពិនិត្យបាន

ទៀតនោះ ច្បាប់អនុញ្ញាតបើកបរធ្វើអាជីវកម្មត្រូវទុកជាមោឃៈ ។ ការតំរូវបន្តរយៈពេលកំណត់ការចរាចរនីមួយៗ ត្រូវមានមូលហេតុច្បាស់លាស់ត្រឹមត្រូវ ។

## ជំពូក VI

## សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន
## សៀវភៅសកម្មភាពជលយាន
## សៀវភៅនិដ្ឋាការធ្វើដំណើរ

### ក-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស :

១- គ្រប់លទ្ធផលនៃការត្រួតពិនិត្យ ត្រូវតែកត់ត្រានៅក្នុងសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ។ សៀវភៅនេះប្រើប្រាស់សំរាប់តែជលយានមួយតែប៉ុណ្ណោះ។

២- សៀវភៅនេះត្រូវអ្នកបើកបររក្សាទុកអោយបានគង់វង្ស និងបង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ចនៅរាល់ពេលត្រួតពិនិត្យ ។ ក្នុងករណីដែលអ្នកបើកបរអោយរហែកបាត់សន្លឹកសៀវភៅនេះ នឹងត្រូវទទួលការពិន័យ ។

៣- សៀវភៅនេះចេញដោយនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

៤- ក្រោយការត្រួតពិនិត្យនីមួយៗ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ត្រូវផ្ញើមកអោយនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹកនូវសេចក្ដីចំលង អំពីការកត់សំគាល់ទាំងឡាយដែលទាក់ទងដល់ការត្រួតពិនិត្យ ការផាកពិន័យលើបទល្មើស ចាប់តាំងពីការត្រួតពិនិត្យជាលើកដំបូងមក ។

ការកត់សំគាល់ទាំងឡាយដែលមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង បានផ្ញើមកនោះ ត្រូវចំលងចូលក្នុងសៀវភៅទុតិយតានៃជលយាននីមួយៗ ដែលនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹកត្រូវរក្សាទុក ដើម្បីតាមដានជាប្រចាំ ។

៥- ការលើកលែងនៃការត្រួតពិនិត្យ ត្រូវបានអនុញ្ញាតចំពោះជលយានដែលត្រូវហាមឃាត់មិនអោយធ្វើចរាចរ ហើយឯកសារចរាចរ ប័ណ្ណសំគាល់ជលយាន ប័ណ្ណបើកបរ ច្បាប់អនុញ្ញាតធ្វើអាជីវកម្ម សៀវភៅពិនិត្យបច្ចេកទេស និងលិខិតប៉ាតង់ពន្ធដារ ត្រូវបានយកមកតំកល់ នៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក និងមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត-ក្រុង ។

៦- ក្នុងករណីដែលសៀវភៅនេះត្រូវបាត់ដោយប្រការណាមួយ អ្នកបើកបរត្រូវទៅរាយការណ៍នៅអង្គភាពនគរបាលមូលដ្ឋានរបស់ខ្លួន រួចហើយត្រូវយកលិខិតបញ្ជាក់ការ

បាត់បង់ ដែលចេញដោយអង្គភាពនគរបាលនោះ មកនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ដើម្បីសុំទុតិយតា ។

៧- ក្នុងករណីដែលសៀវភៅនេះសរសេររលុប់ ទក់ ឬ រលុបអក្សរមើលមិនច្បាស់ ត្រូវមកសុំសៀវភៅថ្មីនៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

## ខ-សៀវភៅសកម្មភាពជលយាន :

១- គ្រប់ជលយានត្រូវតែមានសៀវភៅសកម្មភាពជលយានសំរាប់តាមដាន រាល់សកម្មភាពប្រចាំថ្ងៃ ។

២- បរិបាល ឬ អ្នកបើកបរជលយានត្រូវរក្សាទុកសៀវភៅសកម្មភាពជលយានអោយបានគង់វង់ កុំអោយរហែកបាត់សន្លឹកណាមួយអោយសោះ ហើយត្រូវបង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ចនៅរាល់ពេលត្រួតពិនិត្យ ។

៣- ក្នុងករណីសៀវភៅនេះត្រូវបាត់ បរិបាល ឬ អ្នកបើកបរ ត្រូវរាយការណ៍ជាបន្ទាន់ជូនអង្គភាពនគរបាលនៃមូលដ្ឋានរបស់ខ្លួន រួចហើយយកលិខិតបញ្ជាក់ការបាត់បង់ដែលចេញដោយទីស្នាក់ការនគរបាល មកនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត-ក្រុង ដើម្បីស្នើសុំទិញសៀវភៅថ្មីមួយទៀត ។

៤- ក្នុងករណីសៀវភៅនេះសរសេររលុប់ ទក់ ឬ រលុបអក្សរ មើលមិនឃើញច្បាស់ ត្រូវមកស្នើសុំទិញសៀវភៅថ្មី នៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការដឹកជញ្ជូនខេត្ត-ក្រុង ។

## គ-សៀវភៅទិដ្ឋាការធ្វើដំណើរ :

១- ជលយានគ្រប់ប្រភេទត្រូវតែមានសៀវភៅទិដ្ឋាការធ្វើដំណើរ ។ សៀវភៅនេះចេញដោយនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង នៅពេលបានទទួលច្បាប់អនុញ្ញាតធ្វើអាជីវកម្ម ។

២- សៀវភៅទិដ្ឋាការធ្វើដំណើរនេះ សំរាប់បង្ហាញរាល់ភ្នាក់ងារមានសមត្ថកិច្ចនៅរាល់ប៉ុស្តិ៍ត្រួតពិនិត្យចរាចរផ្លូវទឹក និងកំពង់ផែនៅតាមផ្លូវដែលចូលចត ។

៣- បរិបាល ឬអ្នកបើកបរជលយានត្រូវរក្សាទុក និងថែទាំសៀវភៅនេះអោយបានគង់វង់ កុំអោយបាត់សន្លឹកណាមួយ ។ ក្នុងករណីបាត់សន្លឹកណាមួយនឹងត្រូវទទួលនូវការពិន័យ ។

៤- ក្នុងករណីដែលសៀវភៅនេះត្រូវបាត់ដោយប្រការណាមួយ បរិបាល ឬ អ្នកបើកបរជលយាន ត្រូវរាយការណ៍ជាបន្ទាន់ដល់អង្គភាពនគរបាលនៃមូលដ្ឋានរបស់ខ្លួន រួចហើយយកលិខិតបញ្ជាក់ការបាត់បង់ដែលចេញដោយអង្គភាពនគរបាលនោះ មក

នាយកដ្ឋាន ដឹកជញ្ជូនផ្លូវទឹក ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ដើម្បីស្នើសុំសៀវភៅថ្មីមួយទៀត ។

៥- ក្នុងករណីដែលសៀវភៅនេះសរសេរអស់ ឬទក់ ឬរហែកអក្សរមើលមិនច្បាស់ ត្រូវយកសៀវភៅនេះមកប្តូរយកសៀវភៅថ្មីមួយទៀតនៅនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ នៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

## ជំពូក VII

## ច្បាប់អនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនតាមផ្លូវទឹក

### ក-ច្បាប់អនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក :

ម្ចាស់ជលយានដែលមានបំណងប្រកបអាជីវកម្មដឹកជញ្ជូនផ្លូវទឹក ត្រូវដាក់ពាក្យសុំច្បាប់អនុញ្ញាតធ្វើអាជីវកម្មរបស់ខ្លួនតាមស្ថាប័នដូចមានចែងនៅក្នុងជំពូក I ត្រង់ចំណុច I-1និង I-2 រីឯបេកាក់ព័ន្ធសិទ្ធិ គ្រប់គ្រងដោយលោក ដើរកំណត់តែជាការដឹកអ្នកដំណើរ និងអេតាម ។

ការដាក់ពាក្យសុំច្បាប់អនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន ត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោម ៖

១-ពាក្យសុំមួយច្បាប់ ដែលមានបិទតែមត្រឹមត្រូវ

២-ប័ណ្ណសំគាល់ជលយាន

៣-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស

៤-ប័ណ្ណបើកបរ និង ប័ណ្ណយន្តការី

៥-សៀវភៅទិដ្ឋាការធ្វើដំណើរ

៦-សៀវភៅសកម្មភាពជលយានប្រចាំថ្ងៃ

៧-បង្កាន់ដៃពន្ធដារ

### ខ-ភាតព្វកិច្ចម្ចាស់ជលយាន :

- ម្ចាស់ជលយានត្រូវគោរពតាមពេលម៉ោងចរាចរទិសដៅ និងកម្មវត្ថុនៃការធ្វើអាជីវកម្មដឹកជញ្ជូន ដែលបានកំណត់ក្នុងច្បាប់អនុញ្ញាត ។
- ម្ចាស់ជលយានអាចសុំប្តូរទិស ឬ កម្មវត្ថុធ្វើអាជីវកម្មដែលច្បាប់អនុញ្ញាតនេះបាន លុះត្រាតែខ្លួនបានធ្វើអាជីវកម្មរយៈពេល ៦ខែរួចហើយ ។
- ក្រោយពីបានទទួលច្បាប់អនុញ្ញាត ត្រូវដាក់ជលយានអោយធ្វើអាជីវកម្មក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរបំផុត ចាប់តាំងពីថ្ងៃដែលបានទទួលច្បាប់អនុញ្ញាតរយៈពេល ៣០ថ្ងៃ បើសិនជាម្ចាស់ជលយានមិនអាចដាក់មធ្យោបាយអោយធ្វើអាជីវកម្មបាន ដោយមូលហេតុណាមួយ ត្រូវដាក់ពាក្យសុំពន្យារពេលចរាចរដូចបានរៀបរាប់នៅត្រង់ចំណុច ក នៅក្រសួងសាធារណការ និងដឹកជញ្ជូន (នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក) ឬ នៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ម្ចាស់ជលយានត្រូវរាយការណ៍បញ្ជាក់ពីមូលហេតុពិតប្រាកដ នៃ

ការដែលមិនអាចដាក់អោយដំណើរការធ្វើអាជីវកម្មបាន និងកំណត់រយៈពេលកំណត់ដោយការអោយបានច្បាស់លាស់ ។ ផុតរយៈពេលនេះ ត្រូវសុំបន្តរយៈពេលកំណត់ដោយការទៀត ។ ក្នុងរយៈពេល៤ខែ បើដំណើរការពុំអាចធ្វើចរាចរបាន ច្បាប់អនុញ្ញាតបើកបរធ្វើអាជីវកម្ម ត្រូវចាត់ទុកជាមោឃៈ ។

- ម្ចាស់ជលយានត្រូវបង់ពន្ធដារជូនរដ្ឋអោយបានទៀងទាត់ ។
- ត្រូវអនុវត្តតាមនូវការណែនាំរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន (នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ឬ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ឬ ភ្នាក់ងារមានសមត្ថកិច្ច ដែលបានចារនៅក្នុងសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ) ។
- ម្ចាស់ជលយានមិនត្រូវផ្ទុកទំនិញអ្នកដំណើរនៅលើដំបូលជលយាន និងមិនអោយលើសទំងន់ផ្ទុក ។
- ម្ចាស់ជលយានត្រូវមានធុងផ្ទុកសំរាម ឬ កាកសំណល់ ដើម្បីសងការប៉ះពាល់បរិស្ថាន ។

**គ-ការដកហូតច្បាប់អនុញ្ញាតធ្វើអាជីវកម្ម :**

- ការមិនគោរពបទបញ្ញត្តិខាងលើនេះ ជាកម្មវត្ថុនៃការដកហូតច្បាប់អនុញ្ញាតបើកបរធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក ។
- ការសំរេចដកហូតច្បាប់អនុញ្ញាតធ្វើអាជីវកម្ម ជាសិទ្ធិរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន (នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ) ឬ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

## ជំពូក VIII

## ការត្រួតពិនិត្យលើតំបន់ផែទាំងឡាយ និង កំពង់ដចម្លងនៅក្នុងស្រុក

១- ការត្រួតពិនិត្យលើតំបន់ផែទាំងឡាយ និងកំពង់ដចម្លងនៅក្នុងស្រុក ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ដោយសហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត-ក្រុង ដែលមានតួនាទីជាអ្នកគ្រប់គ្រង ។

- ការត្រួតពិនិត្យនេះត្រូវចាត់តាំងឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូនដែលមានតំណាងនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹកជាប្រធាន ។
- ការត្រួតពិនិត្យនេះសំដៅលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងការចេញ-ចូល ចត តាមទំនើងចិត្តរបស់ម្ចាស់មធ្យោបាយ និងលុបបំបាត់ ទីតាំងកំពង់ផែ និងកំពង់ដចម្លង ខុសច្បាប់ទាំងអស់ ។
- ការពារសុវត្ថិភាពដល់ជលយានគ្រប់ប្រភេទដែល ចេញ ចូល ចត ពិសេសការពារទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋនិងតំរូវអោយម្ចាស់ជលយាន បរិបាល ឬ អ្នកបើកបរតាមច្បាប់របស់រដ្ឋកំណត់ ។

២- ច្បាប់អនុញ្ញាតធ្វើអាជីវកម្មដំបន់កំពង់ផែ និងផតម្លងក្នុងស្រុក :

- ម្ចាស់កំពង់ផែ និងម្ចាស់ផតម្លង ដែលមានបំណងប្រកបរបរអាជីវកម្ម ផែ និង ផតម្លង ត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើអាជីវកម្មរបស់ខ្លួន នៅក្នុងក្រសួងសាធារណការ និងដឹកជញ្ជូន (នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក)
- ការដាក់ពាក្យសុំត្រូវមានសំណុំលិខិតដូចខាងក្រោម :

១- ពាក្យសុំដែលមានបិទតែមត្រឹមត្រូវ មួយច្បាប់
២- លិខិតអនុញ្ញាតសាងសង់ មួយច្បាប់
៣- លិខិតបញ្ជាក់ទីលំនៅ មួយច្បាប់
៤- តំរោងប្រើប្រាស់សំភារៈឧបករណ៍ មួយច្បាប់
៥- បង្កាន់ដៃពន្ធដារ មួយច្បាប់

- ដោយឡែកផតម្លងត្រូវមានបន្ថែម :

១- ប័ណ្ណសំគាល់ជលយាន មួយច្បាប់
២- ប័ណ្ណបើកបរ និង ប័ណ្ណយន្តការី មួយច្បាប់
៣- សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស មួយច្បាប់
៤- សៀវភៅបន្ទុកដែលចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មួយច្បាប់

អគ្គនាយកដ្ឋានរដ្ឋបាល និង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្ត-ក្រុង ត្រូវធ្វើការផ្សព្វផ្សាយសារាចរណែនាំនេះជាបន្ទាន់ ដើម្បីអោយសាធារណជន និងអ្នកពាក់ព័ន្ធនានាបានជ្រាបច្បាស់ ព្រមទាំងអនុវត្តភារកិច្ចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
ហត្ថលេខា និងត្រា
**ឃី តាំងលឹម**

★★★